ក្រសួងអប់រំយុវជននិងកីឡា

MINISTRY OF EDUCATION YOUTH AND SPORTS

សាកលវិទ្យាល័យវ៉ាន់ដា

VANDA UNIVERSITY

# សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ

# អត្ថប្រយោជន៍ដែលទទួលបានពីប្រាក់សោធននៃបេឡាជាតិសន្តិសុខសង្គម

BENEFITS OF THE NATIONAL SOCIAL SECURITY FUND PENSION

ជំនាញ គណនេយ្យ

រាជធានីភ្នំពេញ-ឆ្នាំ២០២៥

PHNOM PENH-2025

ក្រសួងអប់រំយុវជននិងកីឡា
MINISTRY OF EDUCATION YOUTH AND SPORTS
សាកលវិទ្យាល័យវ៉ាន់ដា
VANDA UNIVERSITY

## សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ

# អត្ថប្រយោជន៍ដែលទទួលបានពីប្រាក់សោធននៃបេឡាជាតិសន្តិសុខសង្គម

# BENEFITS OF THE NETIONAL SOCIAL SECURITY FUND PENSION

**គ្រូណែនាំ៖ ហុង ម៉ាលី**

**ជំនាញ គណនេយ្យ**

**រាជធានីភ្នំពេញ-ឆ្នាំ២០២៥**
PHNOM PENH-2025

## គណៈកម្មការត្រួតពិនិត្យសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រជំនាន់ទី២២
## ប្រធានបទៈ អត្ថប្រយោជន៍ដែលទទួលបានពីប្រាក់សោធននៃបេឡាជាតិសន្តិសុខសង្គម

គណៈកម្មការវាយតម្លៃទី១

បេក្ខបណ្ឌិត មាស សំណាង

គ្រូណែនាំ

ហុង ម៉ាលី

គណៈកម្មការវាយតម្លៃទី៣

បេក្ខបណ្ឌិត យ៉ែម សុខហៀក

គណៈកម្មការវាយតម្លៃទី២

បេក្ខបណ្ឌិត យ៉ាក វុទ្ធី

ប្រធានគណៈកម្មការវាយតម្លៃនិងជានាយក
មជ្ឈមណ្ឌលស្រាវជ្រាវ

បណ្ឌិត សេង សំអឿន

អនុប្រធានគណៈកម្មការវាយតម្លៃ និងជានាយក
រងមជ្ឈមណ្ឌលស្រាវជ្រាវ

បេក្ខបណ្ឌិត ស្រេង ផល្លា

**សាកលវិទ្យាធិការ**

**បណ្ឌិត ហេង វ៉ាន់ដា**

សាកលវិទ្យាធិការរងអចិន្ត្រៃយ៍

បណ្ឌិត ហ៊ូ គុជគន្ធលីនណា

# អារម្ភកថា

ក្រោយពីបានសិក្សាថ្នាក់បរិញ្ញាបត្រ ជំនាញ គណនេយ្យ នៅសាកលវិទ្យាល័យវ៉ាន់ដា អស់រយៈពេល ៤ឆ្នាំសិក្សារួចមក ក្រុមយើងខ្ញុំបានទទួលនូវចំណេះដឹងជាច្រើន ពាក់ព័ន្ធនឹងមុខវិជ្ជាគណនេយ្យជាពិសេស ក្រុមយើងខ្ញុំយល់ច្បាស់ថាជំនាញគណនេយ្យគឺជាជំនាញមានសារៈសំខាន់មួយដែរសម្រាប់ទីផ្សារបច្ចុប្បន្ន ក្នុងនោះស្ថាប័នរដ្ឋក្តី ឯកជនក្តី ឬអង្គការក្រៅរដ្ឋាភិបាលក្តី សុទ្ធតែត្រូវអនុវត្តកិច្ចការធនាគារដូចគ្នា។ ដោយឡែកដើម្បីឱ្យការសិក្សារបស់និស្សិតកាន់តែមានគុណភាពខ្ពស់ សាកលវិទ្យាល័យវ៉ាន់ដា បានបញ្ចូលនូវមុខជំនាញសំខាន់ៗដែលពាក់ព័ន្ធនឹងការងារ គណនេយ្យនិងហិរញ្ញវត្ថុនិងធនាគារ តាមកម្មវិធីសិក្សាក្នុងឆ្នាំសិក្សាទីមួយ រហូតដល់ឆ្នាំសិក្សាទី៤។

គ្រប់មុខវិជ្ជាទាំងអស់ សុទ្ធតែមានសារៈសំខាន់ក្នុងការត្រួសត្រាយផ្លូវនិស្សិតឱ្យយល់ច្បាស់ពីការអនុវត្តការងារធនាគារពីការចាប់ផ្តើមរៀបចំផែនការ ការអនុវត្ត ការបញ្ចប់ និងត្រួតពិនិត្យ វាយតម្លៃព្រមទាំងផ្តល់ជាអនុសាសន៍នៅក្នុងការងារធនាគារ ដើម្បីពង្រឹងប្រសិទ្ធភាពគ្រប់គ្រងនៅក្នុងស្ថាប័នខ្លួន ក្នុងន័យឆ្លើយតបឱ្យបានល្អប្រសើរនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាលដែលបានដាក់ចេញ។ដោយក្រុមយើងខ្ញុំសង្កេតឃើញថាកិច្ចការងារមួយនេះមានសារៈសំខាន់ខ្លាំងស្របពេលនៃការសរសេរសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្របានមកដល់ ទើបក្រុមយើងខ្ញុំសម្រេចចិត្តជ្រើសរើសនូវប្រធានបទមួយស្តីពី "**អត្ថប្រយោជន៍ដែលទទួលបានពីប្រាក់សោធននៃបេឡាសន្តិសុខសង្គម**" យកមកធ្វើការសិក្សាស្រាវជ្រាវ និងចងក្រងក្នុងគោលបំណងឱ្យអ្នកស្រាវជ្រាវទាំងអស់ឱ្យយល់កាន់តែស៊ីជម្រៅពីការរៀបចំសារណានិងប្រសិទ្ធភាពនៃការផ្តល់ឥណទានរបស់ធនាគារ។ ក្រុមយើងខ្ញុំសង្ឃឹមថាការរៀបចំសារណានេះ នឹងបានចូលរួមចំណែកក្នុងការស្រាវជ្រាវរបស់និស្សិតជំនាន់ក្រោយៗ ព្រមទាំងអ្នកស្រាវជ្រាវដ៏ទៃទៀតដែលមានបំណងសិក្សាស្វែងយល់ពីកិច្ចការនេះ។

ជាទីបញ្ចប់ក្រុមយើងខ្ញុំ សូមមេត្តាខន្តី អភ័យទោស ពីសំណាក់លោកគ្រូ អ្នកគ្រូ រៀមច្បង និងអ្នកអានទាំងអស់ នូវរាល់កំហុសឆ្គងដែលកើតមានដោយអចេតនា នៅក្នុងសារណានេះ ហើយក្រុមយើងខ្ញុំរីករាយនឹងទទួលយករាល់ការរិះគន់ក្នុងន័យស្ថាបនា ដើម្បីឱ្យការរៀបចំលើកក្រោយទៀតមានភាពកាន់តែល្អប្រសើរ។

# រចនាសម្ព័ន្ធ



សាំង លីស្យា

B22/417



ឡាំ គន្ធា

B22/662



វ៉ន លីហួ

B22/663



ថេង គីមគី

B22/690



ហេង ចាន់ធូ

B22/1146

# សេចក្តីថ្លែងអំណរគុណ

ក្រុមយើងខ្ញុំជានិស្សិតនៃសាកលវិទ្យាល័យវ៉ាន់ដា ថ្នាក់បរិញ្ញាបត្រ ជំនាន់ទី២២ ជំនាញ គណនេយ្យ

**សូមសំដែងនូវការគោរពដឹងគុណ និងថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះ**

ក្រុមគ្រួសារដែលបានជួយឧបត្ថម្ភ គាំទ្រ ទាំងសម្ភារៈ ថវិកា និងស្មារតី ជំរុញលើកទឹកចិត្ត ដល់ក្រុមយើងខ្ញុំ ក្នុងការសិក្សារៀនសូត្រដើម្បីទទួលបានចំណេះដឹងរហូតមកដល់សព្វថ្ងៃនេះ។ ក្នុងនោះក្រុមយើងខ្ញុំសូមសំដែងនូវការគោរព និងកតញ្ញូតាធម៌យ៉ាងជ្រាលជ្រៅបំផុត ដល់អ្នកមានគុណ ដែលបានផ្តល់កំណើតដល់នាងខ្ញុំគ្រប់រូប និងសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ដល់បណ្ដាសាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូទាំងអស់ ដែលបានបណ្តុះបណ្តាលក្រុមយើងខ្ញុំនាពេលកន្លងមក។

ក្រុមយើងខ្ញុំ សូមសំដែងនូវការគោរពដឹងគុណដ៏ជ្រាលជ្រៅដល់ឯកឧត្តមបណ្ឌិត **ហេង វ៉ាន់ដា** នាយកនៃសាកលវិទ្យាធិការ វ៉ាន់ដាដែលបានផ្តល់ទីកន្លែងបណ្តុះបណ្តាល ព្រមទាំងផ្តល់បទពិសោធន៍យ៉ាងច្រើនដល់យើងខ្ញុំ។

សូមគោរពថ្លែងអំណរគុណចំពោះអ្នកគ្រូ **ហុង ម៉ាលី** ជាសាស្ត្រាចារ្យណែនាំ ដោយបានជួយជ្រោមជ្រែង បង្ហាត់បង្ហាញសព្វបែបយ៉ាង ដើម្បីជួយដល់ក្រុមយើងខ្ញុំបញ្ចប់កិច្ចការសារណានេះជាស្ថាពរ។ សូមគោរពថ្លែងអំណរគុណដល់សាស្ត្រាចារ្យ និងបុគ្គលិកនៃសាកលវិទ្យាល័យវ៉ាន់ដា ទាំងអស់ដែលបានខិតខំប្រឹងប្រែងក្នុងការបង្ហាត់បង្ហាញ លើកទឹកចិត្ត អនុគ្រោះដល់ក្រុមយើងខ្ញុំ រហូតធ្វើឱ្យការសិក្សាបានបញ្ចប់ និងទទួលបានជោគជ័យគួរជាទីមោទនៈ។

ឆ្លៀតក្នុងឱកាសនេះដែរ ក្រុមយើងខ្ញុំសូមប្រសិទ្ធពរជ័យជូនដល់បុគ្គលទាំងអស់ខាងលើឱ្យជួបតែពុទ្ធពរបួនប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អំណះអំណាង

ក្រុមនាងខ្ញុំ ជានិស្សិតបរិញ្ញាបត្រ ជំនាញគណនេយ្យនៃសាកលវិទ្យាល័យវ៉ាន់ដា ជំនាន់ទី២២៖ សូមធានាអះអាងថា ខ្លឹមសារសារណាក្រោមប្រធានបទ "អត្ថប្រយោជន៍ដែលទទួលបានពីប្រាក់សោធននៃបេឡាជាតិសន្តិសុខសង្គម" នេះគឺជាស្នាដៃរបស់ក្រុមនាងខ្ញុំ ដោយគ្មានការពាក់ព័ន្ធនឹងរបាយការណ៍ស្រាវជ្រាវរបស់អ្នកផ្សេងឡើយ។ ទិន្នន័យ និងលទ្ធផលនៃការស្រាវជ្រាវ ដែលលើកឡើងនេះ ជាអត្ថបទស្រាវជ្រាវថ្មីសុទ្ធសាធ ដែលពុំធ្លាប់មានជនណាម្នាក់យកទៅប្រើប្រាស់ក្នុងការស្រាវជ្រាវពីមុនឡើយ។

ថ្ងៃ.ពុធ..៨កើត. ខែ.កត្តិក. ឆ្នាំម្សាញ់ សប្តស័ក ព.ស ២៥៦៩

ថ្ងៃទី.២៩. ខែ.តុលា ឆ្នាំ២០២៥

**ហត្ថលេខាតំណាងក្រុម**



សាំង លីស្សា

# សេចក្តីសង្ខេបនៃការស្រាវជ្រាវ

យើងពិនិត្យទៅលើស្ថានភាពជាក់ស្តែងនៅក្នុងប្រទេសកម្ពុជា រាជរដ្ឋាភិបាលបានមើលឃើញនៅការខិតខំប្រឹងប្រែងបំពេញការងាររបស់ប្រជាជនយ៉ាងខ្ជាប់ខ្ជួន ដូចនេះហើយបានជារាជរដ្ឋាភិបាលបានផ្តល់ជំនួយជាអត្ថប្រយោជន៍ ដែលទទួលបានពាក់ពន្ធ័ទៅនឹងប្រាក់សោធននៃបេឡាជាតិសន្តិសុខសង្គម។បើទោះបីជាជាការផ្តល់ជំនួយពិតមែនប៉ុន្តែរាជរដ្ឋាភិបាលតែងតែយកចិត្តទុកដាក់ក្នុងការអភិវឌ្ឍន៍ និងពង្រឹងដល់សន្តិសុខសង្គមជានិច្ច លើសពីនេះរហូតមកដល់បច្ចុប្បន្នបេឡាសុន្តិសុខសង្គមក៏បន្តគ្របដណ្តប់លើវិសាលយ៉ាងធំទូលាយនៅក្នុងប្រទេសកម្ពុជា ដែលបញ្ជាក់បានថាការវិវត្តន៍របស់ប្រព័ន្ធបេឡាសុន្តិសុខសង្គមនៅកម្ពុជាបានបន្តជួយសម្របសម្រួលជាច្រើនដល់និយោជកព្រមទាំងផ្តល់អត្ថប្រយោជន៍ជាសាច់ប្រាក់ច្រើនដល់សមាជិកឬអ្នកក្នុងបន្ទុក។

យោងតាមការស្រាវជ្រាវតាមរយៈវេបសាយនៃបេឡាជាតិសន្តិសុខសង្គមអស់រយៈពេលជាច្រើនខែមកនេះ យើងទទួលបានសមទ្ធិផលគួរជាទីគាប់ចិត្តមួយចំនួនដូចជា ប្រវត្តិនៃបេឡាជាតិសន្តិសុខសង្គម នីតិវិធីនៃការទទួលបានប្រាក់សោធននៃបេឡាជាតិសន្តិសុខសង្គមព្រមទាំងអត្ថប្រយោជន៍ជាច្រើនដែលទទួលបានពាក់ព័ន្ធទៅនឹងប្រាក់សោធននៃបេឡាជាតិសន្តិសុខសង្គម។

ក្រោមការខិតខំប្រឹងប្រែងសិក្សាស្រាវជ្រាវយ៉ាងលម្អិតនិងស្វែងយល់យ៉ាងច្បាស់លាស់ថែមទាំងទទួលបានលទ្ធផលផ្សេងៗដែលយើងចង់បានពីបេឡាជាតិសន្តិសុខសង្គមព្រមទាំងបានរៀបរៀងឡើងជាឯកសារស្រាវជ្រាវមួយច្បាប់នេះទុកជូនលោកគ្រូ អ្នកគ្រូ និងគណៈកម្មការជាអ្នកអានផងដែរ។ សង្ខេបជារួមមកវិញ យើងអាចនិយាយបានថាគ្មានអ្វីដែលល្អឥតខ្ចោះនោះទេ វារមែងតែងតែមានចំណុចខ្វះខាតជៀសមិនផុតឡើយ បើសិនជាក្រុមនាងខ្ញុំមានកំហុសខុសឆ្គងក្នុងប្រការណាមួយសូមលោកគ្រូ អ្នកគ្រូ និងគណៈកម្មការផ្តល់ការអធ្យាស្រ័យដល់ក្រុមនាងខ្ញុំផង។

# មាតិកា

**ទំព័រ**

អារម្ភកថា.......... i
រចនាសម្ព័ន្ធ .......... ii
សេចក្តីថ្លែងអំណរគុណ.......... iii
អំណះអំណាង .......... iv
សេចក្តីសង្ខេបនៃការស្រាវជ្រាវ.......... v


## ជំពូកទី១

## សេចក្តីផ្តើម

១.១ លំនាំបញ្ហានៃការស្រាវជ្រាវ .......... ១
១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ.......... ២
១.៣ គោលបំណងនៃការស្រាវជ្រាវ .......... ២
១.៤ ទំហំដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ.......... ៣
១.៤.១ ទំហំដែនកំណត់នៃការស្រាវជ្រាវ.......... ៣
១.៤.២ វិសាលភាពនៃការស្រាវជ្រាវ .......... ៣
១.៥ វិធីសាស្រ្តនៃការស្រាវជ្រាវ.......... ៣
១.៦ សារៈសំខាន់នៃការស្រាវជ្រាវ.......... ៤
១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ.......... ៥


## ជំពូកទី២

## អត្ថប្រយោជន៍ដែលទទួលបានពីប្រាក់សោធន

២.១ លក្ខណៈទូទៅដែលទទួលបានពីប្រាក់សោធន .......... ៦
២.១.១ និយមន័យប្រាក់សោធន .......... ៨
២.១.២ ប្រវត្តិនៃប្រាក់សោធន .......... ៨
២.១.៣ ទ្រឹស្តីនៃប្រាក់សោធន .......... ៩
២.២. អត្ថប្រយោជន៍ដែលទទួលបានពីប្រាក់សោធននៃបេឡាជាតិសន្តិសុខសង្គម .......... ៩

២.២.១ និយមន័យអត្ថប្រយោជន៍ ..................................................................... ៩
២.២.២ ប្រវត្តិអត្ថប្រយោជន៍ ........................................................................... ៩
២.២.៣ ទ្រឹស្តីនៃអត្ថប្រយោជន៍ ........................................................................ ១០
២.៣ នីតិវិធីដើម្បីទទួលបានពីប្រាក់សោធននៃបេឡាជាតិសន្តិសុខសង្គម ........................ ១០
២.៣.១ និយមន័យសោធន ................................................................................ ១១
២.៣.២ ប្រវត្តិនៃសោធន .................................................................................. ១១
២.៣.៣ ទ្រឹស្តីនៃសោធន .................................................................................. ១១

## ជំពូកទី៣

## អត្ថប្រយោជន៍ដែលទទួលបានពីប្រាក់សោធននៃបេឡាជាតិសន្តិសុខសង្គម

៣.១ ស្ថានភាពទូទៅនៃបេឡាជាតិសន្តិសុខសង្គម ................................................ ១២
៣.១.១ ប្រវត្តិនៃបេឡាជាតិសន្តិសុខសង្គម ........................................................ ១២
៣.១.២ ទស្សនវិស័យ បេសកកម្ម គោលដៅ នៃបេឡាជាតិសន្តិសុខសង្គម ............................ ១៣
៣.១.៣ រចនាសម្ព័ន្ធគ្រប់គ្រង នៃបេឡាជាតិសន្តិសុខសង្គម ............................................ ១៤
៣.២ អត្ថប្រយោជន៍ដែលទទួលបានពីប្រាក់នៃបេឡាជាតិសន្តិសុខសង្គម ............................ ១៥
៣.២.១ ដំណើរការក្នុងការទទួលបានពីប្រាក់សោធន .................................................. ១៥
៣.២.២ ការវាយតម្លៃប្រាក់សោធន ...................................................................... ១៥
៣.២.៣ តួនាទី និងភារៈប្រាក់សោធននៃបេឡាជាតិសន្តិសុខសង្គម .................................... ១៦
៣.៣ នីតិវិធីដើម្បីទទួលបានពីប្រាក់សោធននៃបេឡាជាតិសន្តិសុខសង្គម ........................ ១៧
៣.៣.១នីតិវិធីនៃបេឡាជាតិសន្តិសុខសង្គមបុគ្គលដែលមានសិទ្ធទទួលបានប្រាក់សោធនអំឡុងពេលបំពេញការងារ ........................................................................................... ១៧
៣.៣.២ លក្ខខណ្ឌនៃការប្រើប្រាស់ ...................................................................... ១៨
៣.៣.៣ ការផ្សព្វផ្សាយរបស់បេឡាជាតិសន្តិសុខសង្គម .............................................. ១៩
៣.៣.៤ គម្រោងសមាជិក .................................................................................. ១៩
៣.៣.៥ ការផ្សព្វផ្សាយដោយផ្ទាល់ ...................................................................... ២០
៣.៣.៦ ការផ្សព្វផ្សាយដោយប្រយោល .................................................................. ២១

## ជំពូកទី៤

## ការវិភាគចំណុចខ្លាំងនិង ចំណុចខ្សោយ

៤.១ ការវិភាគចំណុចខ្លាំង ....................................................................................... ២២

៤.២ ការវិភាគចំណុចខ្សោយ ....................................................................................... ២២

## ជំពូកទី៥

## សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

៥.១ សេចក្តីសន្និដ្ឋាន ....................................................................................... ២៤

៥.២ ការផ្តល់អនុសាសន៍ ....................................................................................... ២៤

ឯកសារយោង

ឧបសម្ព័ន្ធ

# ជំពូកទី១
# សេចក្តីផ្តើម

## ១.១ លំនាំបញ្ហានៃការស្រាវជ្រាវ

ការអនុវត្តន៍គោលនយោបាយ "ឈ្នះ ឈ្នះ" នៃប្រមុខរាជរដ្ឋាភិបាលកម្ពុជាបានទទួលជោគជ័យដោយធ្វើឱ្យប្រទេសមានសន្តិភាព និងឯកភាពជាតិពីឆ្នាំ ១៩៩៨ មកម្លេះ ដែលធ្វើឱ្យមានការកែប្រែមុខមាត់ថ្មីនៃព្រះរាជាណាចក្រកម្ពុជា បានបង្ហាញឱ្យឃើញថាកម្ពុជាបាននឹង កំពុងបោះជំហានឥតឈប់ក្នុងឆាកអន្តរជាតិដែលបានសម្រេចនូវកំណើនសេដ្ឋកិច្ចខ្ពស់ និងស្ថេរភាពម៉ាក្រូសេដ្ឋកិច្ចក្នុងបរិមាណអតិផរណាទាបនិងអត្រាប្តូរប្រាក់មានស្ថិរភាពទាំងអស់បានឱ្យឃើញថានេះ ជាចំណុចមួយដែលទាក់ទាញវិនិយោគទុនជាតិ និងអន្តរជាតិមកវិនិយោគទុនជាច្រើនគួរឱ្យកត់សម្គាល់ដែលជាចំណុចធ្វើឱ្យប្រមុខរាជរដ្ឋាភិបាលបាននឹងបន្តការយកចិត្តទុកដាក់លើមន្ត្រីរាជការសាធារណៈ និងកម្មករនិយោជិតគ្រប់ទាំងវិស័យទាំងអស់នូវកម្ពុជា។ចំពោះកិច្ចគាំពារសង្គមដល់ប្រជាពលរដ្ឋខ្លួនតាមរយៈគោលនយោបាយជាតិគាំពារសង្គមដែរ ក្នុងមានពីរប្រព័ន្ធគឺប្រព័ន្ធជំនួយសង្គម និងប្រព័ន្ធសន្តិសុខសង្គម។ ដោយប្រើការបង្កើតច្បាប់ស្តីពីរបបសន្តិសុខសង្គមនូវកម្ពុជាដោយស្ថាប័នប្រតិបត្តិនោះគឺបេឡាជាតិសន្តិសុខសង្គម។

បេឡាជាតិសន្តិសុខសង្គមដែលហៅកាត់ថា បេឡាជាតិសន្តិសុខសង្គម (ប.ស.ស) គឺជាស្ថាប័នប្រតិបត្តិករតែមួយគត់ដែលធ្វើឱ្យប្រតិបត្តិការលើរបបសន្តិសុខសង្គម ដូចមានចែងក្នុងបទបញ្ញត្តិនៃច្បាប់នេះ។ បេឡាជាតិសន្តិសុខសង្គមជាគ្រឹះស្ថានសាធារណៈរដ្ឋបាលដែលត្រូវបង្កើតឡើងដោយព្រះរាជក្រឹត្យស្ថិតក្រោមអាណាព្យាបាលបច្ចេកទេសនៃក្រសួងការងារបណ្តុះបណ្តាលវិជ្ជាជីវៈទទួលបន្ទុកវិស័យរបបសន្តិសុខសង្គម និងស្ថិតក្រោមអាណាព្យាបាលបច្ចេកទេសនៃក្រសួងការងារបណ្តុះបណ្តាលវិជ្ជាជីវៈ ទទួលបន្ទុកវិស័យរបបសន្តិសុខសង្គម និងស្ថិតក្រោមអាណាព្យាបាលហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ដើម្បីធានាបាននូវការទូទាត់សំណង និងសមភាពការងារផ្សេងៗដែលបានកើតឡើងចំពោះកម្មករនិយោជិតនៅឆ្នាំ ១៩៥៥ កម្ពុជាបានបង្កើតឱ្យមានរបបសន្តិសុខសង្គមសម្រាប់ធានាឱ្យបាននូវអត្ថប្រយោជន៍នៃការទទួលបានប្រាក់សោធនចំពោះកម្មករនិយោជិតនាសម័យនោះ ប៉ុន្តែរឿងដែលគួរឱ្យសោកស្តាយរបស់ទាំងនេះត្រូវបានបំភ្លេចបំផ្លាញចោលទាំងស្រុង។ក្នុងរបបដ៏ខ្មៅងងឹតនោះគឺ របបប្រល័យពូជសាសន៍នៅក្នុងឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩។ ប្រជាពលរដ្ឋទទួលបានអត្ថប្រយោជន៍ជាច្រើនពីសំណាក់បេឡាជាតិសន្តិសុខសង្គម ហើយក្រោយពីការបោះឆ្នោត ក្នុងអំឡុងឆ្នាំ ១៩៩៣ នាយកដ្ឋានសន្តិសុខសង្គម បែបបង្កើតឡើងជាថ្មីម្តងទៀត។ ដោយនាយកដ្ឋានមួយនេះ មានភារកិច្ចទទួលខុសត្រូវអនុវត្តកិច្ចគាំពារសង្គមដល់ប្រជាពលរដ្ឋ ក្នុងវិស័យឯកជន ដែលមានការយកចិត្តទុកដាក់របស់ប្រមុខរដ្ឋរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ទើបរដ្ឋាភិបាលបានសម្រេចបង្កើតឡើងដោយច្បាប់ស្តីពីរបបសន្តិសុខសង្គម សម្រាប់ជនទាំងឡាយណាដែលស្ថិតក្រោមបទបញ្ញត្តិនៃច្បាប់ស្តីពីការងារតាមរយៈច្បាប់នេះបានឈានដល់ការបង្កើតគ្រឹះស្ថានសាធារណៈមួយនេះឡើងនៅថ្ងៃទី ០២ ខែមីនា ឆ្នាំ២០០៧ ដោយអនុក្រឹត្យលេខ ១៦ អនក្រ បក ស្តីពីការបង្កើតបេឡាជាតិសន្តិសុខសង្គម និងលេចចេញជារូបរាងជាផ្លូវការនៅថ្ងៃទី ១១ ខែកុម្ភៈ ឆ្នាំ២០០៨។

បេឡាជាតិសន្តិសុខសង្គម (ប.ស.ស) គឺជាស្ថាប័នដែលមានការរីកចម្រើនមកយ៉ាងឥតឈប់ឈរ និងប្រកបដោយប្រសិទ្ធភាពក្នុងការអនុវត្តន៍នយោបាយគាំពារសង្គម។សកម្មភាពនេះបានធ្វើឱ្យប្រមុខរដ្ឋាភិបាលបន្ថែមទទួលខុសត្រូវទៅលើមន្ត្រីរាជការសាធារណៈ អតីតមន្ត្រី និងអតីតយុទ្ធជន។ ក្នុងការអនុវត្តន៍នេះ ត្រូវបានធ្វើវិសោធនកម្មច្បាប់របស់ប.ស.ស នៅឆ្នាំ២០០២ ដោយអនុវត្តជាផ្លូវការនៅឆ្នាំ២០១៩ ហើយក៏បានប្តូរជា អគ្គនាយកដ្ឋានបេឡាជាតិសន្តិសុខសង្គម នៅឆ្នាំ២០២០។ ការអនុវត្តន៍នេះបានធ្វើឱ្យមានការចុះខាងលើអត្ថប្រយោជន៍ជាច្រើនសម្រាប់និយោជិត និងសមាជិក រួមមានការបង់ប្រាក់សោធន និងការព្យាបាលតាមបែបវេជ្ជសាស្ត្រ។ ប៉ុន្តែមានការយល់ដឹងកម្រិតតិចតួចពីសេវាកម្មនេះដែលនាំឱ្យមានការខាតបង់អត្ថប្រយោជន៍ពី បេឡាជាតិសន្តិសុខសង្គមប្រើប្រាស់ប្រាក់សោធន និងសេវាសុខាភិបាលនេះ ជួយសម្រួលនូវការរស់នៅ និងទប់ស្កាត់ភាពក្រីក្រ របស់អ្នកប្រឈមមុខនឹងភាពលំបាកក្នុងសង្គម។ ដោយសារតែការរីកចម្រើននៃវិស័យសុខាភិបាលនៅកម្ពុជា ក្រុមនាងខ្ញុំបានសម្រេចចិត្តជ្រើសយកប្រធានបទ «**អត្ថប្រយោជន៍ដែលទទួលបានពីប្រាក់សោធននៃបេឡាជាតិសន្តិសុខសង្គម**» ដើម្បីស្រាវជ្រាវសម្រាប់សារណាបញ្ចប់ឆ្នាំសិក្សា។

## ១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ

បេឡាជាតិសន្តិសុខសង្គម គឺជាចំណែកមួយដែលបានចូលរួមក្នុងការ ពង្រីកសន្តានុពលយ៉ាងខ្លាំងខ្លា ដោយយោងតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជាដោយភាពបត់បែន និងច្នៃប្រឌិតខ្ពស់របស់ថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់ពីបេឡាជាតិសន្តិសុខសង្គមបាននិងបន្តការផ្តល់ជាប្រយោជន៍ដល់សមាជិកខ្លួនដោយឥតឈប់ឈរជាងមួយសតវត្សន៍មកហើយ។ ការកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំនៃសមាជិកពីបេឡាជាតិសន្តិសុខសង្គមបានបោះជំហានទៅមុខក្នុងការធានាឱ្យបាននៅនិរន្តភាព ការប្រើប្រាស់របស់សេវាសមាជិកខ្លួនទើបមាន ការចុះកិច្ចព្រមព្រៀងជាមូលដ្ឋានសុខាភិបាលរដ្ឋ និងឯកជនជាច្រើនក្នុងព្រះរាជាណាចក្រកម្ពុជា។ កាលណាប្រទេសជាតិបាននឹងកំពុងរីកចម្រើន ក្នុងវិស័យនេះបានធ្វើឱ្យមានកត្តាជំរុញដល់វិស័យសុខាភិបាលនៅក្នុងប្រទេសនេះឱ្យកាន់តែមានការរីកចម្រើនជឿនលឿនទៅតាមនោះដែរ។ ដែលនេះហើយនាំឱ្យមានជាបញ្ហាចោទជាសំណួរជាច្រើនទាក់ទងទៅនិងទទួលបានពីប្រាក់សោធននៃបេឡាជាតិសន្តិសុខសង្គម។ ក្នុងនោះផងដែរក្រុមយើងខ្ញុំបានយកសំណួរ ពីរ មកធ្វើការចោទសួរៈ

១.តើអត្ថប្រយោជន៍ដែលទទួលបានពីប្រាក់សោធននៃបេឡាជាតិសន្តិសុខសង្គមមានអ្វីខ្លះ ?

២.តើមាននីតិវិធីអ្វីខ្លះ ដើម្បីទទួលបានពីប្រាក់សោធននៃបេឡាជាតិសន្តិសុខសង្គម ?

## ១.៣ គោលបំណងនៃការស្រាវជ្រាវ

គោលបំណងនៃការស្រាវជ្រាវ គឺជាផ្នែកសំខាន់នៃការស្រាវជ្រាវនៃការរាយការណ៍នូវគោលបំណងរបស់អង្គភាពនូវអ្វីដែលអង្គភាពសង្ឃឹមថាត្រូវសម្រេចឱ្យបានជាមួយនឹងការសិក្សាស្រាវជ្រាវ និងឆ្លុះបញ្ចាំងពីប្រសិទ្ធភាពក្នុងការបង្កើតបេឡាជាតិសន្តិសុខសង្គម ដោយផ្តោតទៅលើចំណុចសំខាន់មួយដូចខាងក្រោម ៖

- ចក្ខុវិស័យ និងបេសសកកម្មរបស់បេឡាជាតិសន្តិសុខសង្គម
- តួនាទី និងរចនាសម្ព័ន្ធរបស់បេឡាជាតិសន្តិសុខសង្គម
- ស្វែងយល់អំពីតួនាទីយ៉ាងលម្អិតពីប្រតិបត្តិកររបស់បេឡាជាតិសន្តិសុខសង្គម

➢ យល់ដឹងពីអត្ថប្រយោជន៍ដែលទទួលបានពីប្រាក់សោធននៃបេឡាសន្តិសុខសង្គម
➢ ស្វែងយល់ពីស្ថានភាពនៃដំណើរការនៃការប្រតិបត្តិនៃបេឡាជាតិសន្តិសុខសង្គម
➢ ស្វែងយល់ពីភាពបត់បែននៃការដំណើរការនៃបច្ចេកទេសរបស់ បេឡាជាតិសន្តិសុខសង្គមស្មេរភាពដល់សមាជិក
➢ស្វែងយល់អំពីបញ្ហាប្រឈមរបស់ស្ថាប័នប្រតិបត្តិករនេះនៃបេឡាជាតិសន្តិសុខសង្គមដើម្បីជានានូវស្ថិរភាពរបស់សមាជិក ដើម្បីបញ្ចៀសឱ្យបាននូវការបាត់បង់អត្ថប្រយោជន៍។
➢ យល់ដឹងពីការចុះឈ្មោះរបស់បេឡាជាតិសន្តិសុខសង្គម
➢ យល់ដឹងពីអត្ថប្រយោជន៍នៃការចូលជាសមាជិករបស់បេឡាជាតិសន្តិសុខសង្គម

## ១.៤ ទំហំដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

### ១.៤.១ ទំហំដែនកំណត់នៃការស្រាវជ្រាវ

ការស្រាវជ្រាវប្រធានបទ**“អត្ថប្រយោជន៍ដែលទទួលបានពីប្រាក់សោធននៃបេឡាជាតិសន្តិសុខសង្គម”** នៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងការធានាបាននូវ សមធម៌និងសាមគ្គីធម៌សង្គម និងដើម្បីលើកកម្ពស់សុខុមាលភាព និងជីវភាពរបស់ប្រជាពលរដ្ឋ ដោយធានានូវសន្តិសុខប្រាក់នៅពេលជួបហានិភ័យសង្គមរួមចំណែក កាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់ស្ថិរភាពសង្គម ដែលបញ្ជាក់ឱ្យឃើញនូវការយកចិត្តទុកដាក់ពីប្រមុខរាជរដ្ឋាភិបាល ក្នុងការធានានិរន្តរភាពដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋទាំងបច្ចុប្បន្នក៏ ដូចជានាពេលអនាគត ដែលមានអាសយដ្ឋាន អាគារទីស្នាក់ការកណ្តាល បេឡាជាតិសន្តិសុខសង្គម ផ្លូវបេតុង សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ។

### ១.៤.២ វិសាលភាពនៃការស្រាវជ្រាវ

បេឡាជាតិសន្តិសុខសង្គម ជាប្រភេទគ្រឹះស្ថានរដ្ឋបាលសាធារណៈដែលមានវិសាលភាពគ្របដណ្តប់លើគ្រប់វិស័យ និងការគាំពារឱ្យមានរបបសន្តិសុខសង្គមនូវកម្ពុជា នៅក្នុងឆ្នាំ ២០២២។ តួយ៉ាងការប្រែប្រួលបទបញ្ញត្តិ និងកំណែទម្រង់នីតិវិធីរដ្ឋផ្សេងៗ។ល។ ក្នុងសម័យកាលដែលសេដ្ឋកិច្ចប្រទេសមានការប្រែប្រួលឥតឈប់ឈរនៃកំណើនសេដ្ឋកិច្ច និងនយោបាយប្រទេសតម្រូវឱ្យមានការលេចឡើងនូវបញ្ហាជាច្រើនដែលនាំឱ្យមានកិច្ចគាំពារសង្គមផ្សេងៗ ទៅលើវិស័យឯកជននិងវិស័យសាធារណៈ ទៅលើការគាំពារសុខភាពសាធារណៈជាចំណុចដែលមិនខ្វះបាននោះឡើយ នូវរបបសន្តិសុខសង្គមដែលក្រោមការដឹកនាំរបស់ថ្នាក់ដឹកនាំរបស់បេឡាជាតិសន្តិសុខសង្គមគ្រប់ជាន់ថ្នាក់។

## ១.៥ វិធីសាស្ត្រនៃការស្រាវជ្រាវ

ការស្រាវជ្រាវតាមបែបគុណវិស័យ ដោយផ្តោតទៅលើការវិភាគទិន្នន័យបន្ទាប់សន្សំ( Secondary Data ) បានមកពីគេហទំព័របណ្តាញសង្គមបេឡាជាតិសន្តិសុខសង្គម និងប្រភពបណ្តាញសង្គម (Social media) ដែលពាក់ព័ន្ធទៅនឹងប្រធានបទ ដើម្បីយកមកវិភាគ និងសិក្សាស្រាវជ្រាវ ក្នុងគោលបំណងបញ្ជាក់អំពីព័ត៌មានដែលទាក់ទងទៅលើប្រាក់សោធននៃបេឡាជាតិសន្តិសុខសង្គមនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

សម្រាប់សំណួរទី១៖ ត្រូវបានប្រមូលតាមបែបគុណវិស័យបានមកពីគេហទំព័របណ្តាញសង្គមបេឡាជាតិសន្តិសុខសង្គមមួយចំនួនបានបញ្ជាក់យ៉ាងច្បាស់អំពី អត្ថប្រយោជន៍ដែលទទួលបានពីប្រាក់សោធននៃបេឡាជាតិសន្តិសុខសង្គម។

សម្រាប់សំណួរទី២៖ ត្រូវបានប្រមូលតាមគុណវិស័យបានមកពីគេហទំព័របណ្តាញសង្គមបេឡាជាតិសន្តិសុខសង្គម និងប្រភពបណ្តាញសង្គម (Social Media)។ ទិន្នន័យដែលបានប្រមូលពីក្នុងវេបសាយទាំងនេះដើម្បីជាគោលបំណងយល់ដឹងពីនីតិវិធី ដើម្បីទទួលបានប្រាក់សោធនពីបេឡាជាតិសន្តិសុខសង្គម។

## ១.៦ សារៈសំខាន់នៃការស្រាវជ្រាវ

ការស្រាវជ្រាវនេះធ្វើឡើង គឺមានសារៈសំខាន់ចង់ឱ្យប្រជាជនទាំងអស់បាន សិក្សាស្វែងយល់ឱ្យកាន់តែច្បាស់អំពី ដំណើរនៃការទទួលបានប្រាក់សោធននៃបេឡាជាតិសន្តិសុខសង្គមផងដែរ ដែលមានអត្ថប្រយោជន៍ជាច្រើនដូចជា៖

• ចំពោះអ្នកស្រាវជ្រាវ (Reseachers):

➢ យល់ដឹងបេឡាជាតិផ្តល់ព័ត៌មានស្ថិតិប្រាក់សោធន និងការអប់រំដល់ប្រជាពលរដ្ឋ

➢ យល់ដឹងពីផ្នែកសង្គមវិទ្យា បច្ចេកវិទ្យា ឬសេដ្ឋកិច្ចអាចយកប្រព័ន្ធសន្តិសុខសង្គមជាជាតុសិក្សា

➢ ស្គាល់ពីប្រតិបត្តិការ ការគ្រប់គ្រង និងការផ្តត់ផ្គង់សេវាកម្មគាំពារសង្គមដោយបេឡាជាតិសន្តិសុខសង្គម

➢ អាចស្វែងយល់ពីដំណើរការនៃបទពិសោធន៍ដែលទទួលបាន នូវបេឡាជាតិសន្តិសុខសង្គមធ្លាប់ទទួលបានឆ្លងកាត់ជាច្រើនឆ្នាំមកនេះ

➢ អាចស្វែងយល់ពីផលវិជ្ជមាន និងអវិជ្ជមាននៃការប្រើប្រាស់សេវាកម្មរបស់បេឡាជាតិសន្តិសុខសង្គម

➢ បង្កើនសមត្ថភាពក្នុងក្រុម

➢ អាចឱ្យនិស្សិតជំនាន់ក្រោយធ្វើការសិក្សាស្រាវជ្រាវបន្តទៀតដោយមានភាពងាយស្រួល។

➢ អាចមានឱកាសសហការជាមួយបេឡាជាតិសន្តិសុខសង្គម ដើម្បីចូលរួមក្នុងគម្រោងជាតិក្នុងការផ្តល់យោបល់លើនយោបាយថ្មីៗ។

• ចំពោះស្ថាប័ន (Institutions):

➢ យល់ដឹងពីស្ថាប័នចម្រុះគាំពារសង្គមដែលមានលក្ខណៈស្តង់ដាដូចជា បេឡាជាតិសន្តិសុខសង្គម

➢ ជួយបុគ្គលិកជានាសុវត្ថិភាពផ្នែកហិរញ្ញវត្ថុ សម្រាប់ពួកគេពេលចូលនិវត្តន៍

➢ លើកទឹកចិត្តកាន់តែខ្លាំង អំឡុងពេលធ្វើការប្រកបដោយប្រសិទ្ធភាព និងការបេជ្ញាចិត្តចំពោះសហគ្រាស

➢ ផ្តល់ផែនការប្រាក់សោធនដ៏ល្អ មានកេរ្តិ៍ឈ្មោះល្អ ដែលអាចទាក់ទាញអតិថិជន និងដៃគូសក្តានុពល

➢ អាចជួយដល់ស្ថាប័នដែលចាប់អារម្មណ៍ទៅលើ បេឡាជាតិសន្តិសុខសង្គមអាចសិក្សាស្វែងយល់ បានយ៉ាងស៊ីជម្រៅបន្ថែមទៀតទៅលើដំណាក់កាលនីមួយៗប្រតិបត្តិការដែលកំពុងប្រើប្រាស់។

• ចំពោះសង្គមជាតិ (Society):

➢ បង្កើតបរិយាកាសឱ្យអាជីវកម្មរីកចម្រើន និងបង្កើតការងារក្នុងសង្គមជាតិ

➢ ប្រព័ន្ធសន្តិសុខសង្គមប្រសើរ ធ្វើឱ្យប្រជាពលរដ្ឋមានជំនឿលើរដ្ឋាភិបាល និងគោរពតាមច្បាប់

➢ ជួយបង្កើនប្រាក់ចំណូល នៅពេលដែលសាមីខ្លួនបាត់បង់សមត្ថភាពការងារ ឬចូលដល់វ័យចាស់ជរាចាប់ពីអាយុ៦០ឆ្នាំឡើងទៅ

➢ ជួយលើកកម្ពស់សេដ្ឋកិច្ចជាតិ និងការរីកចម្រើនរបស់សហគមន៍

➢ ជួយកាត់បន្ថយអំពីឧក្រិដ្ឋកម្ម និងបញ្ហាសង្គមនានា។

## ១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

នៅក្នុងសារណាបញ្ចប់ការសិក្សានេះគឺ យើងបានបែងចែកជាបីជំពូកសំខាន់ រួមមានដូចខាងក្រោម៖

**ជំពូកទី១** ៖ នៅជំពូកនេះយើងផ្តោតសំខាន់ទៅលើរំលឹកទ្រឹស្តី ព្រមទាំងរៀបរាប់លម្អិតអំពីប្រភេទនៃរបបមួយចំនួន ការប្រែប្រួលនៃស្ថាប័នប្រតិបត្តិករ និងដំណើរការវិវត្តន៍របស់ប្រព័ន្ធសន្តិសុខសង្គមដោយក្នុងនោះយើងបានយកទាំងគុណសម្បត្តិ និងគុណវិបត្តិមួយចំនួនមកធ្វើការបកស្រាយផងដែរ។

**ជំពូកទី២** ៖ យើងសិក្សាទៅលើស្ថានភាពទូទៅរបស់បេឡាជាតិសន្តិសុខសង្គម ដំណើរវិវត្តន៍របស់បេឡាជាតិមកដល់បច្ចុប្បន្ននេះ ទស្សនៈវិស័យ បេសកកម្ម គោលដៅ នៃបេឡាជាតិសន្តិសុខសង្គមនៅក្នុងប្រទេសកម្ពុជា។

**ជំពូកទី៣**៖ នៅក្នុងជំពូកនេះ យើងបានធ្វើការសិក្សាស្រាវជ្រាវទៅលើប្រតិបត្តិការ ការប្រើប្រាស់បច្ចេកទេសនានា របស់បេឡាជាតិសន្តិសុខសង្គម ដែលក្នុងនោះក៏មានចេញនូវលទ្ធផលនៃការស្រាវជ្រាវទាំងបញ្ហាប្រឈម និងអត្ថប្រយោជន៍ដែលកើតចេញពីបច្ចេកទេសលើប្រព័ន្ធសន្តិសុខសង្គមផងដែរ។

**ជំពូកទី៤**៖ ជំពូកនេះយើងធ្វើការវិភាគទៅលើចំណុចទាំងអស់ ដែលបានអនុវត្ត គឺក្នុងគោលបំណងវិភាគឱ្យឃើញនូវចំណុចខ្វះខាតទាំងឡាយដើម្បីធ្វើការកែលម្អបន្ថែម។

**ជំពូកទី៥**៖ ធ្វើការសន្និដ្ឋានទៅលើគ្រប់ចំណុចទាំងអស់ និងផ្តល់ជាយោបល់អនុសាសន៍ទៅលើចំណុចដែលត្រូវកែលម្អ។

# ជំពូកទី២
# អត្ថប្រយោជន៍ដែលទទួលបានពីប្រាក់សោធន

## ២.១ លក្ខណៈទូទៅដែលទទួលបានពីប្រាក់សោធន

តាមរយៈការដាក់ឱ្យដំណើរការរបបសន្តិសុខសង្គម ផ្នែកប្រាក់សោធន គឺជាការធានាបាននូវសង្គមភាពរវាងបុគ្គលត្រូវគាំពារទាំងបីក្រុមរួមមាន បុគ្គលស្ថិតនៅក្នុងវិស័យសាធារណៈ បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ដោយរួមបញ្ចូលទាំងបុគ្គលិកធ្វើការតាមផ្លូវអាកាស និងនាវិកសមុទ្រ ព្រមទាំងអ្នកបម្រើក្នុងផ្ទះ និងបុគ្គលស្វ័យនិយោជន៍ ដោយផ្នែកនេះត្រូវបានបែងចែកចេញជា២ គឺផ្នែកប្រាក់សោធនតាមរបបភាគទានជាកាតព្វកិច្ច និងតាមរបបភាគទានដោយស្ម័គ្រចិត្ត។តាវកាលិកផ្នែកប្រាក់សោធនរួមមាន សោធនជរាភាព សោធនទុព្វលភាព សោធនឧត្តរជីវី និងវិភាជន៍បូជាសព។

តាវកាលិកផ្នែកប្រាក់សោធនតាមរបបភាគទានជាកាតព្វកិច្ចមានដូចខាងក្រោម៖

### ក. សោធនជរាភាព

សមាជិក បេឡាជាតិសន្តិសុខសង្គម ដែលមានអាយុយ៉ាងតិច ៦០(ហុកសិប)ឆ្នាំ មានសិទ្ធទទួលបានសោធនជរាភាពប្រសិនបើសាមីជនបានបំពេញលក្ខខណ្ឌដូចខាងក្រោម៖

១-បានចុះបញ្ជីក្នុងផ្នែកប្រាក់សោធន។

២- បានបង់ភាគទានផ្នែកប្រាក់សោធនយ៉ាងតិច១២(ដប់ពីរ)ខែ។

### ខ. សោធនជរាភាពអយ្យកប្បញ្ញត្តិ

តាវកាលិកនេះ ត្រូវបានផ្តល់ជូនរយៈពេល៣៦ខែរាប់ចាប់ពីការដាក់ឱ្យអនុវត្តរបបសន្តិសុខសង្គម សមាជិក បេឡាជាតិសន្តិសុខសង្គមជាកម្មករនិយោជិតមានសិទ្ធិទទួលបានសោធនជរាភាពអយ្យកប្បញ្ញត្តិ ត្រូវបំពេញលក្ខខណ្ឌគិតចាប់ពីកាលបរិច្ឆេទនៃការចាប់ផ្តើមដំណើរការដំបូងនៃផ្នែកប្រាក់សោធនដូចខាងក្រោម៖

- មានអាយុលើសពី៣០(សាមសិប)ឆ្នាំ គិតត្រឹមថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២២
- បានបង់ភាគទានយ៉ាងតិច២៤(ម្ភៃបួន)ខែ ក្នុងរយៈពេល៣៦(សាមសិប)ខែគិតចាប់ពីកាលបរិច្ឆេទថ្ងៃទី ០១ ខែតុលា ឆ្នាំ២០២២។

### គ. សោធនទុព្វលភាព

សមាជិកបេឡាជាតិសន្តិសុខសង្គម ជាកម្មករនិយោជិត ដែលធ្លាក់ខ្លួនទុព្វលភាព មានសិទ្ធិទទួលបានប្រាក់សោធនទុព្វលភាព ប្រសិនបើសាមីជនបានបំពេញលក្ខខណ្ឌដូចខាងក្រោម៖

១- បានចុះបញ្ជីក្នុងផ្នែកប្រាក់សោធន

២- បានបង់ភាគទានផ្នែកប្រាក់សោធនយ៉ាងតិច៦០(ហុកសិប)ខែ មុនកាលបរិច្ឆេទទទួលរង ទុព្វលភាព។ កម្រិតអប្បបរមានៃសោធនទុព្វលភាព ត្រូវកំណត់ស្មើនឹង៤៥%(សែសិបប្រាំភាគរយ) នៃប្រាក់ឈ្នួលមធ្យមបង់ភាគទានរបស់សាមីជន។

### ឃ. សោធនឧត្តរជីវី

សិទ្ធិវន្តនៃសោធនឧត្តរជីវី មានសិទ្ធិទទួលបានសោធនឧត្តរជីវី លុះត្រាតែមានការទទួលមរណភាពនៃសាមីជនជាសោធនិកជរាភាព ឬទុព្វលភាព ឬសមាជិក បេឡាជាតិសន្តិសុខសង្គម បានបង់ភាគទានផ្នែកប្រាក់សោធនយ៉ាងតិច៦០(ហុកសិប)ខែ។

ចំណែកសោធនឧត្តរជីវី ត្រូវបានបែកចែកដូចខាងក្រោម៖

- សម្រាប់សហព័ទ្ធ៥០% (ហាសិបភាគរយ)
- សម្រាប់កូន៥០% (ហាសិបភាគរយ)
- ក្នុងករណីដែលសិទ្ធិវន្តមានតែសហព័ទ្ធ ឬកូន ត្រូវទទួលបាន១០០% (មួយរយភាគរយ)។

សិទ្ធិវន្តនៃសោធនឧត្តរជីវី ត្រូវបំពេញទម្រង់ទាមទារតាវកាលិកនេះក្នុងអំឡុងពេល៣(បី) ខែបន្ទាប់ពីកាលបរិច្ឆេទទទួលមរណភាពនៃសាមីជនជាសោធនិកជរាភាពឬទុព្វលភាពឬសមាជិកបេឡាជាតិសន្តិសុខសង្គមដែលបានបង់ភាគទានយ៉ាងតិច៦០(ហុកសិប)ខែ។

### ង. វិភាជន៍បូជាសព

សិទ្ធិវន្តនៃសោធនឧត្តរជីវីមានសិទ្ធិទទួលបានវិភាជន៍បូជាសពស្មើនឹង ៥(ប្រាំ)ខែនៃប្រាក់សោធនចុងក្រោយរបស់សោធនិក ឬអប្បបរមា ២ ០០០ ០០០រៀល នៅពេលដែលសោធនិកទទួលមរណភាព។ ប្រសិនបើករណីកិច្ចនេះមិនបានបំពេញដោយសិទ្ធិវន្តនៃសោធនឧត្តរជីវី វិភាជន៍បូជាសព អាចត្រូវផ្តល់ដល់ជនណាដែលជាអ្នកចាត់ចែងបូជាសពសាមីជនផ្ទាល់។

លក្ខខណ្ឌនៃការទទួលបានវិភាជន៍បូជាសពត្រូវកំណត់ដូចខាងក្រោម៖

- ជូនដំណឹងមក បេឡាជាតិសន្តិសុខសង្គម អំពីមរណភាពរបស់សោធនិកក្នុងរយៈពេលយ៉ាងយូរ២(ពីរ)សប្តាហ៍ គិតចាប់ពីកាលបរិច្ឆេទទទួលមរណភាព
- បំពេញទម្រង់ស្នើសុំវិភាជន៍បូជាសពដោយភ្ជាប់ជាមួយនូវសំបុត្រមរណភាព ឬឯកសារផ្សេងៗដែលទទួលស្គាល់ដោយ បេឡាជាតិសន្តិសុខសង្គម ។

សិទ្ធិវន្តនៃសោធនឧត្តរជីវី ឬបុគ្គលចាត់ចែងបូជាសពសោធនិក ត្រូវបំពេញទម្រង់ទាមទារតាវកាលិកវិភាជន៍បូជាសពយ៉ាងយូរ៣(បី)ខែ បន្ទាប់ពីកាលបរិច្ឆេទសោធនិកទទួលមរណភាព។

បេឡាជាតិសន្តិសុខសង្គមនឹងចេញសេចក្តីសម្រេច ផ្តល់វិភាជន៍បូជាសពក្នុងរយៈពេល២(ពីរសប្តាហ៍)គិតចាប់ពីកាលបរិច្ឆេទទទួលពាក្យស្នើសុំ។ តាវកាលិកសោធនជរាភាព ទុព្វលភាព និងសោធនឧត្តរជីវី ត្រូវគិតចាប់ពីកាលបរិច្ឆេទនៃការទាមទារ។ ក្នុងករណីខកខានការទាមទារដោយករណីប្រធានសក្តិ សាមីជនអាចទាមទារអវសិដ្ឋ ហើយអវសិដ្ឋនេះត្រូវផ្តល់ជូនតាមការសម្រេចរបស់ក្រុមប្រឹក្សាភិបាលនៃ បេឡាជាតិសន្តិសុខសង្គម [1]។

[1] ច្បាប់ស្តីពីរបបសន្តិសុខសង្គម ប្រលាសឱ្យប្រើនៅថ្ងៃទី១៨ ខែតុលា កថាភាគទី២ ផ្នែកប្រាក់សោធនតាមរបបភាគទានជាកាតព្វកិច្ចសម្រាប់បុគ្គលទាំងឡាយណាដែលស្ថិតក្រោមបទប្បញ្ញត្តិស្តីពីការងារ ដោយរួមបញ្ចូលទាំងបុគ្គលិកធ្វើការតាមផ្លូវអាកាសនិងនាវាសមុទ្រ ព្រមទាំងអ្នកបម្រើក្នុងផ្ទះ មាត្រា៣១ មាត្រា៣២ មាត្រា៣៣ មាត្រា៣៤

**២.១.១ និយមន័យប្រាក់សោធន**

ប្រាក់សោធន គឺប្រៀបបានទៅនិងផែនការសន្សំប្រាក់រយៈពេលវែងដោយមិនដឹងខ្លួន ដែលទទួលបានផលតបស្នងត្រលប់មកវិញនៅពេលដែលសាមីខ្លួនបាត់បង់សមត្ថភាពការងារ ឬចូលដល់វ័យចាស់ជរាចាប់ពីអាយុ៦០ឆ្នាំឡើងទៅ[2]។

**២.១.២ ប្រវត្តិនៃប្រាក់សោធន**

របបសន្តិសុខសង្គមត្រូវបានរកឃើញក្នុងសតវត្សទី១៩ នៅតាមបណ្តាប្រទេសអឺរ៉ុបក្នុងទម្រង់ជំនួយសង្គមរបស់សមាគម ឬអង្គការស្ម័គ្រចិត្ត ដែលផ្តល់ទៅឱ្យសមាជិករបស់ខ្លួន ឬជនក្រីក្រ។ ក្នុងឆ្នាំ១៨៨៤ ប្រទេសអាឡឺម៉ង់បានចាប់ផ្តើមមានប្រព័ន្ធធានារ៉ាប់រងសង្គមផ្នែកមនុស្សចាស់ បន្ទាប់មកក្លាយជាកម្មវិធីធានារ៉ាប់រងសង្គមផ្នែកជំងឺ ដែលមានលក្ខណៈទូលំទូលាយក្នុងប្រទេសរបស់ខ្លួន ដោយផ្អែកលើគោលការណ៍ធានារ៉ាប់រងសង្គម។ យ៉ាងណាមិញ ពាក្យថា "សន្តិសុខសង្គម" គឺត្រូវបានបង្កើត និងមានការទទួលស្គាល់នៅថ្ងៃទី១៤ ខែសីហា ឆ្នាំ១៩៣៥ ដោយសហរដ្ឋអាមេរិកតាមរយៈច្បាប់សន្តិសុខសង្គម ដែលមានការរួមបញ្ចូលគ្នានៃពាក្យ សន្តិសុខសេដ្ឋកិច្ច និងពាក្យ ធានារ៉ាប់រងសង្គម ក្រោយមកពាក្យ "សន្តិសុខសង្គម" ត្រូវបានយកមកប្រើប្រាស់ និងមានការទទួលស្គាល់ជា សកលលោកក្នុងឆ្នាំ១៩៤៨ តាមរយៈសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស មាត្រា២២ ដែលបានកំណត់ថា "មនុស្សគ្រប់រូបក្នុងនាមជាសមាជិកនៃសង្គមមានសិទ្ធិទទួលបានសន្តិសុខសង្គម"។ "សន្តិសុខសង្គម" ត្រូវបានផ្តល់និយមន័យផ្សេងៗគ្នា ទៅតាមការអនុវត្តរបស់ប្រទេស អង្គការ ឬស្ថាប័ននីមួយៗ យ៉ាងនេះក្តី ពាក្យខាងលើនេះអាចសង្កត់នូវចំណុចរួមមួយគឺ វិធានការឱ្យសមាជិកសង្គមរស់នៅក្នុងបរិបទសមធម៌ និងសាមគ្គីធម៌សង្គម ដើម្បីការពារគ្នាទៅវិញទៅមកកុំឱ្យធ្លាក់ចូលស្ថានភាពក្រីក្រ ជួយទប់ទល់នឹងហានិភ័យសង្គម ធានាសន្តិសុខប្រាក់ចំណូល លើកកម្ពស់សុខុមាលភាព និងជីវភាពរស់នៅក្នុងភាពសមរម្យថ្លៃថ្នូរ។ របបសន្តិសុខសង្គមបានចាប់កំណើតនៅព្រះរាជាណាចក្រកម្ពុជាក្នុងឆ្នាំ១៩៤០ ក្នុងទម្រង់ជាប្រព័ន្ធតាវកាលិកគ្រួសារ "ហឹបប្រាក់អន្តរវិជ្ជាជីវៈ" ក្រោយពីព្រះរាជាណាចក្រកម្ពុជាទទួលបានឯករាជ្យពីអាណានិគមបារាំង ច្បាប់ស្តីពីការបង្កើតហឹបប្រាក់អន្តរវិជ្ជាជីវៈសម្រាប់ទូទាត់វិភាជន៍គ្រួសារត្រូវបានប្រកាសឱ្យប្រើដោយក្រមលេខ ៣ន.ស ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ១៩៥៥ ស្របតាមច្បាប់នេះ "ហឹបប្រាក់អន្តរវិជ្ជាជីវៈសម្រាប់ទូទាត់វិភាជន៍គ្រួសារ" ត្រូវបានបង្កើតឡើងដោយព្រះរាជក្រឹត្យលេខ ៣០៦ន.ស។ ជាអកុសល ព្រះរាជាណាចក្រកម្ពុជាបានធ្លាក់ចូលក្នុងវិនាសកម្មដ៏ខ្មៅងងឹតក្រោមរបបកម្ពុជាប្រជាធិបតេយ្យ (របបប្រល័យពូជសាសន៍ប៉ុល-ពត ឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ដែលបានធ្វើឱ្យរបបសន្តិសុខសង្គមត្រូវបានលុបបំបាត់ចោល និងបាននាំឱ្យប្រទេសធ្លាក់ដល់ក្រោមចំណុចសូន្យ។ ក្រោយរបបកម្ពុជាប្រជាធិបតេយ្យបានដួលរលំនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ របបសន្តិសុខសង្គមបានចាប់ផ្តើមមានជាថ្មីផ្នែកប្រាក់សោធនរបស់មន្ត្រីសាធារណៈ និងផ្នែកប្រាក់ប៉ះពាល់សុខភាពកម្មករនិយោជិតដែលធ្វើការនៅតាមរោងចក្រសហគ្រាសរដ្ឋ ដែលអនុវត្តដោយនាយកដ្ឋានបៀវត្សពលកម្មនៃក្រសួងផែនការ។ បន្ទាប់ពីការបោះឆ្នោតឆ្នាំ១៩៩៣ នាយកដ្ឋានសន្តិសុខសង្គមត្រូវបានបង្កើតឡើងស្ថិតក្រោមក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន បន្ទាប់មកចាប់ពីឆ្នាំ២០០៥ បានស្ថិតក្រោមក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីទទួលបន្ទុកក្នុងការរៀបចំកិច្ចការគតិយុត្ត សម្រាប់ការអនុវត្តរបបសន្តិសុខសង្គមដល់បុគ្គលដែលធ្វើការ

[2] អនុក្រឹត្យលេខ ៣២ អនក្រ.បកចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០២១ ចេញដោយរាជរដ្ឋាភិបាលកម្ពុជា ស្តីពីរបបសន្តិសុខសង្គមផ្នែកប្រាក់សោធន

ក្នុងវិស័យឯកជនក្នុងឆ្នាំ២០០២ ច្បាប់ស្ដីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយ ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិ នៃច្បាប់ស្ដីពីការងារ ត្រូវបានអនុម័តឱ្យប្រើប្រាស់យ៉ាងទូលំទូលាយដល់កម្មករនិយោជិត រហូតដល់ឆ្នាំ២០០៧ នាយកដ្ឋានសន្តិសុខសង្គមបានប្ដូរមកជា បេឡាជាតិរបបសន្តិសុខសង្គម ដើម្បីទទួលបន្ទុកអនុវត្តច្បាប់ខាងលើឱ្យកាន់តែមានប្រសិទ្ធភាព។ ដោយទទួលបានជោគជ័យគួរជាទីគាប់ចិត្ត ក្នុងការដាក់ឱ្យអនុវត្តរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារក្នុងឆ្នាំ២០០៨ ទើបរាជរដ្ឋាភិបាលបានបង្កើតរបបសន្តិសុខសង្គម ផ្នែកថែទាំសុខភាពក្នុងឆ្នាំ២០១៦ សម្រាប់ជនទាំងឡាយ ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិ នៃច្បាប់ស្ដីពីការងារ ដែលមិនធ្លាប់មានក្នុងប្រវត្តិសាស្ត្រកម្ពុជា ក្រោយអនុវត្តទទួលបានជោគជ័យលើវិស័យឯកជន រាជរដ្ឋាភិបាលបានផ្ដល់សេចក្ដីទុកចិត្តលើបេឡាជាតិសន្តិសុខសង្គមដោយប្រគល់ភារកិច្ចបន្ថែមលើការអនុវត្តរបបសន្តិសុខសង្គមចំពោះបុគ្គល នៃវិស័យសាធារណៈ។ បេឡាជាតិរបបសន្តិសុខសង្គម វិវឌ្ឍន៍ខ្លួនទៅជាគ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលមានឈ្មោះថា បេឡាជាតិសន្តិសុខសង្គមនិងជាប្រតិបត្តិករតែមួយគត់ដែលធ្វើប្រតិបត្តិការរបបសន្តិសុខសង្គម ផ្នែកប្រាក់សោធន ផ្នែកថែទាំសុខភាព ផ្នែកហានិភ័យការងារ និងផ្នែកនិកម្មភាពការងារដែលបង្កើតដោយព្រះរាជក្រឹត្យលេខ នស/រកត/០៥២០/៥៨២ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២០ [3]។

### ២.១.៣ ទ្រឹស្ដីនៃប្រាក់សោធន

ទ្រឹស្ដីនៃប្រាក់សោធន ជារបបសន្តិសុខសង្គមផ្នែកប្រាក់សោធនសម្រាប់បុគ្គលនៃវិស័យសាធារណៈ ត្រូវមានលក្ខណៈជារបបភាគទានជាកាតកិច្ចដែលរដ្ឋនិងបុគ្គលនៃវិស័យសាធារណៈមានកាតកិច្ចរួមគ្នាក្នុងការបង់ភាគទាន។ របបសន្តិសុខសង្គមផ្នែកប្រាក់សោធនសម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញតិនៃច្បាប់ស្ដីពីការងារ ដោយរួមបញ្ចូលទាំងបុគ្គលិកធ្វើការតាមផ្លូវអាកាសនិងនាវាសមុទ្រ ព្រមទាំងអ្នកបម្រើក្នុងផ្ទះ មានកាតព្វកិច្ចរួមគ្នាក្នុងការភាគទាន[4]។

## ២.២. អត្ថប្រយោជន៍ដែលទទួលបានពីប្រាក់សោធននៃបេឡាជាតិសន្តិសុខសង្គម

### ២.២.១ និយមន័យអត្ថប្រយោជន៍

និយមន័យអត្ថប្រយោជន៍ គឺជាប្រាក់ដែលរាជរដ្ឋាភិបាលផ្ដល់ឱ្យប្រជាជនដែលមានសិទ្ធទទួលបានក្នុងប្រព័ន្ធសង្គម ដើម្បីជួយគ្រប់គ្រងប្រព័ន្ធជាតិពិសេសសម្រាប់អ្នកដែលមានរបួសឬមានភាពអសមត្ថភាព។ នេះជាអត្ថប្រយោជន៍សង្គមសម្រាប់អ្នកដែលបានចូលរួមក្នុងប្រព័ន្ធសន្តិសុខសង្គម និងបានបង់ប្រាក់បង់ប្រាក់តាមលក្ខខណ្ឌដែលមានសិទ្ធិទទួល[5]។

### ២.២.២ ប្រវត្តិអត្ថប្រយោជន៍

ប្រវត្តិអត្ថប្រយោជន៍ គឺតំណាងឱ្យប្រព័ន្ធការពារសង្គមដែលមានគោលបំណងផ្ដល់ការជំនួយទៅកាន់មនុស្សដែលត្រូវបានប៉ះពាល់ពីស្ថានភាពខុសគ្នា ឬមានភាពងាយរងគ្រោះ។ ប្រព័ន្ធសន្តិសុខសង្គមរបស់

[3] ច្បាប់ស្ដីពីរបបសន្តិសុខសង្គម ប្រកាសឱ្យប្រើនៅថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ ២០១៩ ជំពូកទី២ គោលការណ៍ទូទៅនៃរបបសន្តិសុខសង្គម មាត្រា៥ ផ្នែកប្រាក់សោធន

[4] អនុក្រឹត្យលេខ ៣២ អនក្រ.បក ចុះថ្ងៃទី ០៤ ខែមីនា ឆ្នាំ ២០២១ ស្ដីពីរបបប្រាក់សោធននិវត្តន៍នៃបេឡាជាតិរបបសន្តិសុខសង្គម មាត្រា ៦ មាត្រា ១១ និង មាត្រា ១២

[5] អនុក្រឹត្យលេខ ៣២ អនក្រ.បក ចុះថ្ងៃទី ០៤ ខែមីនា ឆ្នាំ ២០២១ ស្ដីពីរបបប្រាក់សោធននិវត្តន៍នៃបេឡាជាតិរបបសន្តិសុខសង្គម មាត្រា ៣

បេឡាគឺជាការអនុវត្តន៍ធំមួយដែលមានមូលដ្ឋានពីការជួយបង្ក្រាបភាពអតីត និងជានាថាប្រជាជនមានសិទ្ធទទួលបានការថែទាំ។ ហេតុដូច្នេះ ទើបបង្កើតឱ្យមានប្រព័ន្ធសន្តិសុខសង្គមដំបូងត្រូវបានបង្កើតនៅក្នុងបេឡាក្រោមសេដ្ឋកិច្ច និងសង្គមក្រោយសង្គ្រាមពិភពលោកទីពីរ។ តាំងពេលនោះមក ការអភិវឌ្ឍន៍សង្គមត្រូវបានគ្រប់គ្រងដោយរដ្ឋដើម្បីធានានូវសិទ្ធិ និងអត្ថប្រយោជន៍សង្គមសម្រាប់មនុស្សទាំងអស់។ក្នុងឆ្នាំ ១៩៤៤ ប្រព័ន្ធសង្គមបានចាប់ផ្តើមផ្តល់ជំនួយនានាជូនប្រជាជនដែលពិតជាមានការទទួលនូវអត្ថប្រយោជន៍សង្គម ដូចជា ប្រាក់ជំនួយចំពោះអ្នកមានការលំបាក ជាមួយសេវាសុខាភិបាលបាន។បន្ទាប់ពីការអភិវឌ្ឍន៍ប្រព័ន្ធសង្គមប្រកបដោយភាពទាំងមូល នៃគោលការណ៍សម្រាប់សន្និដ្ឋានសង្គម ប្រព័ន្ធនេះបានធ្វើការកែប្រែជាច្រើនដើម្បីបង្កើតការលើកស្ទួយក្នុងការចូលរួម និងការផ្តល់ជូនសេវាសង្គមល្អប្រសើរជាមួយសេវាកម្មអប់រំ និងការជួយសង្គមផងដែរ[6]។

**២.២.៣ ទ្រឹស្តីនៃអត្ថប្រយោជន៍**

នីតិវិធីដែលទទួលបានប្រាក់សោធននៃបេឡាជាតិសន្តិសុខសង្គមមានគោលបំណងបញ្ជាក់នូវការប្រើប្រាស់ប្រាក់សោធនសម្រាប់អ្នកដែលមានសិទ្ធិប្រើប្រាស់ និងធានាសុខុមាលភាពសង្គមដល់ពួកគេ។ ក្នុងចំណោមនីតិវិធីនេះ មានទ្រឹស្តីនៃអត្ថប្រយោជន៍ជាចម្បងដែលពាក់ព័ន្ធនឹងការអនុម័ត និងការផ្តល់ប្រាក់សោធនទៅឱ្យប្រជាជនប្រើប្រាស់រួមមានទ្រឹស្តីដូចជា[7]៖

➢ទ្រឹស្តីនៃការធានាសុខុមាលភាពៈ ផ្តល់ជំនួយដល់បុគ្គលដែលមានភាពខ្វះខាត ដូចជា អាយុចាស់ ឬការសម្រេចលើសុខភាព។វាផ្តល់ជំនួយធនាគារដល់បុគ្គលដែលគ្មានសេចក្តីសម្រេចចិត្តក្នុងការងារតាមសមត្ថភាពរបស់ពួកគេ។

➢ទ្រឹស្តីនៃសិទ្ធិគ្រួសារៈ គ្រួសារត្រូវបានចូលរួមទាំងការកំចាត់បំណុលចំពោះបុគ្គលដែលធ្លាក់ចុះក្នុងជីវភាពលំបាក។ ប្រើប្រាស់ប្រាក់សោធននោះ អាចដើម្បីជួយគ្រួសារ (ដូចជាការអប់រំនៃកុមារ, ការថែទាំសមាជិកជំងឺ)។

➢ទ្រឹស្តីនៃការយកចិត្តទុកដាក់លើសុខភាពៈ ដើម្បីការជួយសង្គ្រោះសុខភាពលើការបាត់បង់ប្រាក់ចំណូលនៃបុគ្គល និងគ្រួសារដែលមានជំងឺ ឬការរីកចម្រើននៃភាពរឹងមាំ។

## ២.៣ នីតិវិធីដើម្បីទទួលបានពីប្រាក់សោធននៃបេឡាជាតិសន្តិសុខសង្គម

នីតិវិធីដែលទទួលបានពីប្រាក់សោធននៃបេឡាជាតិសន្តិសុខសង្គម មានចំណុចដែលត្រូវបានបំពាក់ទៅលើការទទួលសិទ្ធិដូចជា ៖

➢ការចូលរួមៈ មនុស្សដែលចូលរួមក្នុងប្រព័ន្ធបេឡាជាតិសន្តិសុខសង្គមត្រូវតែមានការចុះបញ្ជី និងបង់ប្រាក់ប្រចាំខែ ដោយសារតែការបង់ប្រាក់នេះប្រើប្រាស់សម្រាប់ការកំណត់ប្រាក់ដែលត្រូវបានផ្តល់ទៅឱ្យពួកគេចំពោះការព្យាបាល ឬអត្ថប្រយោជន៍សង្គមផ្សេងៗ។

➢ការស្នើសុំប្រាក់សោធនៈ មនុស្សដែលមានសិទ្ធិទទួលប្រាក់សោធនត្រូវតែស្នើសុំមកពីអាជ្ញាធរ សុខាភិបាល ឬមធ្យោបាយផ្សេងៗ ដូចជា តាមប្រព័ន្ធអ៊ីនធឺណិតឬទូរស័ព្ទ។

[6] ព្រះរាជក្រមលេខ នស/រកម/១១១៩/០១៨ ចុះថ្ងៃទី ២ ខែវិច្ឆិកា ឆ្នាំ ២០១៩ ស្តីពីច្បាប់ស្តីពីសន្តិសុខសង្គម

[7] គោលនយោបាយសន្តិសុខសង្គមជាតិកម្ពុជា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងធនាគារពិភពលោក ឆ្នាំ ២០២០

➢ការពិនិត្យសិទ្ធិៈ អាជ្ញាធរពិនិត្យសិទ្ធិគ្រប់គ្រងឱ្យអាចទទួលបានការអះអាងពីអត្ថប្រយោជន៍ផ្សេងៗ ដែលបានបង់ប្រាក់ចូលទៅក្នុងប្រព័ន្ធសង្គមសេវា។

➢ការបញ្ជូនប្រាក់ៈ ប្រាក់សោធនត្រូវបានបញ្ជូនទៅអ្នកស្នើសុំដែលមានសិទ្ធិ ។

➢ ការសងប្រាក់បន្តៈ ក្នុងករណីសន្និដ្ឋានប្រាក់ពីរយៈពេលលំបាក ឬការចូលរួមថ្មី អ្នកទទួលអាចបន្តប្រើប្រាស់បង្ហាញជាអត្ថប្រយោជន៍ចាប់ពីការផ្តល់ប្រាក់ឡើងវិញ[8]។

### **២.៣.១ និយមន័យសោធន**

និយមន័យសោធន គឺជាប្រាក់ជំនួយដែលរដ្ឋផ្តល់ឱ្យប្រជាជនដើម្បីជានាសុខុមាលភាពសង្គម និងសុខភាព នៅពេលដែលមានករណីពិបាក ឬបញ្ហាសុខភាពដែលប៉ះពាល់ដល់សមត្ថភាពការងារ។ វារួមបញ្ចូលទៅនិងការសង្គ្រោះផ្សេងទាក់ទងនិងអត្រាអាជីព, សុខភាព, ការជួយគ្រួសារ, ការជួយសង្គ្រោះសម្រាប់អ្នកដែលមានការរីកចម្រើនលើសុខភាព និងអត្ថប្រយោជន៍ផ្សេងទៀតដែលរដ្ឋបានកំណត់[៩]។

### **២.៣.២ ប្រវត្តិនៃសោធន**

ប្រវត្តិនៃសោធន ក្នុងបេឡាជាតិសន្តិសុខសង្គម គឺជាព័ត៌មានដែលត្រូវបានចម្លង និងចូលរួមជាមួយនឹងការអភិវឌ្ឍន៍នយោបាយសង្គមនៃប្រទេស បេឡាដែលទាក់ទងទៅនឹងប្រព័ន្ធសង្គម និងការប្រើប្រាស់ប្រាក់សង្គម។នៅក្នុងបេឡា មានប្រព័ន្ធសន្តិសុខសង្គមដែលមានការផ្តល់សេវាកម្មទៅកាន់ប្រជាជន។ ប្រព័ន្ធនេះរួមមានការផ្តល់ប្រាក់ជំនួយ ឬជំនួយផ្សេងៗ ដូចជា៖

➢**ប្រាក់ជំនួយសង្គម**: សម្រាប់អ្នកដែលមានភាពពិការភាព ឬអ្នកដែលមិនអាចធ្វើការបាន។

➢**សេវាសុខាភិបាល**: មានប្រព័ន្ធសុខាភិបាលសម្រាប់អ្នកដែលទ្រូវការជំនួយច្បាស់លាស់ក្នុងការទទួលបានការថែទាំសុខភាព។ប្រព័ន្ធនេះត្រូវបានប្រើប្រាស់ក្នុងការស្តារជំនួយសង្គមឱ្យអាចធ្វើឱ្យប្រជាជនមានស្ថានភាពកាន់តែប្រសើរនៅក្នុងការរស់នៅ[10]។

### **២.៣.៣ ទ្រឹស្តីនៃសោធន**

ទ្រឹស្តីនៃសោធន គឺជាការពិចារណាពីការជួយសង្គមឬការជួយផ្តល់ការពារជីវិត សម្រាប់ប្រជាពលរដ្ឋដែលមានស្ថានភាពលំបាកឬមិនមានសុវត្ថិភាពក្នុងការរស់នៅ។ ប្រាក់សោធននៃបេឡាជាតិសន្តិសុខសង្គម គឺជាជំនួយហិរញ្ញវត្ថុដែលផ្តល់ជួយដល់អ្នកដែលមានភាពខកខាន ឬមានភាពក្រីក្រក្នុងសង្គម[11]។

---

[8] ច្បាប់ស្តីពីរបបសន្តិសុខសង្គម ប្រលាសឱ្យប្រើនៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២៩ ជំពូកទី២ គោលការណ៍ទូទៅនៃរបបសន្តិសុខសង្គម មាត្រា៣៥ ផ្នែកប្រាក់សោធន

[9] ព្រះរាជក្រមលេខ នស/រកម/១១១៩/០១៨ ចុះថ្ងៃទី ២ ខែវិច្ឆិកា ឆ្នាំ ២០១៩ ស្តីពីច្បាប់ស្តីពីសន្តិសុខសង្គម

[10] អនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២ ខែមិថុនា ឆ្នាំ ២០០៧ ស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស.)

[11] ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គមរបស់កម្ពុជា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងធនាគារពិភពលោក ឆ្នាំ ២០២០

# ជំពូកទី៣
# អត្ថប្រយោជន៍ដែលទទួកបានពីប្រាក់សោធន
# នៃបេឡាជាតិសន្តិសុខសង្គម

## ៣.១ ស្ថានភាពទូទៅនៃបេឡាជាតិសន្តិសុខសង្គម

### ៣.១.១ ប្រវត្តិនៃបេឡាជាតិសន្តិសុខសង្គម

របបសន្តិសុខសង្គមត្រូវបានរកឃើញក្នុងសតវត្សទី១៩ នៅតាមបណ្តាប្រទេសអឺរ៉ុបក្នុងទម្រង់ជំនួយសង្គមរបស់សមាគម ឬអង្គការស្ម័គ្រចិត្ត ដែលផ្តល់ទៅឱ្យសមាជិករបស់ខ្លួន ឬជនក្រីក្រ។ ក្នុង ឆ្នាំ១៨៨៤ ប្រទេសអាឡឺម៉ង់បានចាប់ផ្តើមមានប្រព័ន្ធធានារ៉ាប់រងសង្គមផ្នែកមនុស្សចាស់ បន្ទាប់មកក្លាយជាកម្មវិធីធានារ៉ាប់រងសង្គមផ្នែកជំងឺ ដែលមានលក្ខណៈទូលំទូលាយក្នុងប្រទេសរបស់ខ្លួន ដោយផ្អែកលើគោលការណ៍ធានារ៉ាប់រងសង្គម។ យ៉ាងណាមិញ ពាក្យថា "សន្តិសុខសង្គម" គឺត្រូវបានបង្កើត និងមានការទទួលស្គាល់នៅថ្ងៃទី ១៤ ខែសីហា ឆ្នាំ១៩៣៥ ដោយសហរដ្ឋអាមេរិចតាមរយៈច្បាប់សន្តិសុខសង្គម ដែលមានការរួមបញ្ចូលគ្នានៃពាក្យ សន្តិសុខសេដ្ឋកិច្ច និងពាក្យ ធានារ៉ាប់រងសង្គម ក្រោយមកពាក្យ "សន្តិសុខសង្គម" ត្រូវបានយកមកប្រើប្រាស់ និងមានការទទួលស្គាល់ជា សកលលោកក្នុងឆ្នាំ១៩៤៨ តាមរយៈសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស មាត្រា២២ ដែលបានកំណត់ថា "មនុស្សគ្រប់រូបក្នុងនាមជាសមាជិកនៃសង្គមមានសិទ្ធិទទួលបានសន្តិសុខសង្គម"។ "សន្តិសុខសង្គម" ត្រូវបានផ្តល់និយមន័យផ្សេងៗគ្នា ទៅតាមការអនុវត្តរបស់ប្រទេស អង្គការ ឬស្ថាប័ននីមួយៗ យ៉ាងនេះក្តី ពាក្យខាងលើនេះអាចសង្កត់នូវចំណុចរួមមួយគឺ វិធានការឱ្យសមាជិកសង្គមរស់នៅក្នុងបរិបទសមធម៌ និងសាមគ្គីធម៌សង្គម ដើម្បីការពារគ្នាទៅវិញទៅមកកុំឱ្យធ្លាក់ចូលស្ថានភាពក្រីក្រ ជួយទប់ទល់នឹងហានិភ័យសង្គម ធានាសន្តិសុខប្រាក់ចំណូល លើកកម្ពស់សុខុមាលភាព និងជីវភាពរស់នៅក្នុងភាពសមរម្យថ្លៃថ្នូរ។ របបសន្តិសុខសង្គមបានចាប់កំណើតនៅព្រះរាជាណាចក្រកម្ពុជាក្នុងឆ្នាំ ១៩៤០ ក្នុងទម្រង់ជាប្រព័ន្ធតាវកាលិកគ្រួសារ "ហឹបប្រាក់អន្តរវិជ្ជាជីវៈ" ក្រោយពីព្រះរាជាណាចក្រកម្ពុជាទទួលបានឯករាជ្យពីអាណានិគមបារាំង ច្បាប់ស្តីពីការបង្កើតហឹបប្រាក់អន្តរវិជ្ជាជីវៈសម្រាប់ទូទាត់វិភាជន៍គ្រួសារ ត្រូវបានប្រកាសឱ្យប្រើដោយក្រមលេខ៣ន.ស ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ១៩៥៥ ស្របតាមច្បាប់នេះ "ហឹបប្រាក់អន្តរវិជ្ជាជីវៈសម្រាប់ទូទាត់វិភាជន៍គ្រួសារ" ត្រូវបានបង្កើតឡើងដោយព្រះរាជក្រឹត្យលេខ ៣០៦ន.ស។ ជាអកុសល ព្រះរាជាណាចក្រកម្ពុជាបានធ្លាក់ចូលក្នុងវិនាសកម្មដ៏ខ្មៅងងឹងក្រោមរបបកម្ពុជាប្រជាធិបតេយ្យ(របបប្រល័យពូជសាសន៍ប៉ុល-ពត ឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩) ដែលបានធ្វើឱ្យរបបសន្តិសុខសង្គមត្រូវបានលុបបំបាត់ចោល និងបាននាំឱ្យប្រទេសធ្លាក់ដល់ក្រោមចំណុចសូន្យ។ ក្រោយរបបកម្ពុជាប្រជាធិបតេយ្យបានដួលរលំនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ របបសន្តិសុខសង្គមបានចាប់ផ្តើមមានជាថ្មីផ្នែកប្រាក់សោធនរបស់មន្ត្រីសាធារណៈ និងផ្នែកប្រាក់ប៉ះពាល់សុខភាពកម្មករនិយោជិតដែលធ្វើការនៅតាមរោងចក្រសហគ្រាសរដ្ឋ ដែលអនុវត្តដោយនាយកដ្ឋានបៀវត្សពលកម្មនៃក្រសួងផែនការ។ បន្ទាប់ពីការបោះឆ្នោតឆ្នាំ១៩៩៣ នាយកដ្ឋានសន្តិសុខសង្គមត្រូវបានបង្កើតឡើងស្ថិតក្រោមក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន បន្ទាប់មកចាប់ពីឆ្នាំ២០០៥ បានស្ថិតក្រោមក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីទទួលបន្ទុកក្នុងការរៀបចំកិច្ចការគតិយុត្តសម្រាប់ការអនុវត្តរបបសន្តិសុខសង្គមដល់បុគ្គលដែលធ្វើការក្នុងវិស័យ

ឯកជន។ ក្នុងឆ្នាំ២០០២ ច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយ ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិ នៃច្បាប់ស្តីពីការងារ ត្រូវបានអនុម័តឱ្យប្រើប្រាស់យ៉ាងទូលំទូលាយដល់កម្មករនិយោជិត រហូតដល់ឆ្នាំ២០០៧ នាយកដ្ឋានសន្តិសុខសង្គមបានប្តូរមកជា បេឡាជាតិរបបសន្តិសុខសង្គម ដើម្បីទទួលបន្ទុកអនុវត្តច្បាប់ខាងលើឱ្យកាន់តែមានប្រសិទ្ធភាព។ ដោយទទួលបានជោគជ័យគួរជាទីមោទនភាព ក្នុងការដាក់ឱ្យអនុវត្តរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារក្នុងឆ្នាំ២០០៨ ទើបរាជរដ្ឋាភិបាលបានបង្កើតរបបសន្តិសុខសង្គម ផ្នែកថែទាំសុខភាពក្នុងឆ្នាំ២០១៦ សម្រាប់ជនទាំងឡាយ ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិ នៃច្បាប់ស្តីពីការងារ ដែលមិនធ្លាប់មានក្នុងប្រវត្តិសាស្ត្រកម្ពុជា ក្រោយអនុវត្តទទួលបានជោគជ័យលើវិស័យឯកជន រាជរដ្ឋាភិបាលបានផ្តល់សេចក្តីទុកចិត្តលើ បេឡាជាតិសន្តិសុខសង្គមដោយប្រគល់ភារកិច្ចបន្ថែមលើការអនុវត្តន៍របបសន្តិសុខសង្គមចំពោះបុគ្គល នៃវិស័យសាធារណៈ។ នេះជាកាលានុវត្តភាពឱ្យ បេឡាជាតិរបបសន្តិសុខសង្គម វិវឌ្ឍខ្លួនទៅជាគ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលមានឈ្មោះថា បេឡាជាតិសន្តិសុខសង្គមនិងជាប្រតិបត្តិករតែមួយគត់ដែលធ្វើប្រតិបត្តិការរបបសន្តិសុខសង្គម ផ្នែកប្រាក់សោធន ផ្នែកថែទាំសុខភាព ផ្នែកហានិភ័យការងារ និងផ្នែកនិកម្មភាពការងារ ដែលបង្កើតដោយព្រះរាជក្រឹត្យលេខ នស/រកត/០៥២០/៥៨២ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២០ ។

### ៣.១.២ ទស្សនវិស័យ បេសកកម្ម គោលដៅ នៃបេឡាជាតិសន្តិសុខសង្គម

#### ក.ទស្សនវិស័យ

ជានាសន្តិសុខសង្គមប្រកបដោយសមធម៌ និងសាមគ្គីធម៌សង្គម ដើម្បីលើកកម្ពស់សុខុមាលភាពនិងជីវភាពប្រជាពលរដ្ឋ។

#### ខ.បេសកកម្ម

ផ្តល់សេវាផ្នែកសន្តិសុខសង្គម ប្រកបដោយប្រសិទ្ធភាព និរន្តរភាព និងសង្គតិភាព សម្រាប់បុគ្គលដែលស្ថិតក្នុងវិស័យសាធារណៈបុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីការងារដោយរួមបញ្ចូលទាំងបុគ្គលិកធ្វើការតាមផ្លូវអាកាស និងនាវាសមុទ្រព្រមទាំងអ្នកបម្រើក្នុងផ្ទះ និង បុគ្គលស្វ័យនិយោជន៍។

#### គ.គោលដៅ

១. ពង្រឹង និងពង្រីកការអនុវត្តន៍របបសន្តិសុខសង្គមផ្នែកហានិភ័យការងារ
២. ពង្រឹង និងពង្រីកការអនុវត្តន៍របបសន្តិសុខសង្គមផ្នែកថែទាំសុខភាព
៣. ពង្រឹង និងពង្រីកការអនុវត្តន៍របបសន្តិសុខសង្គមផ្នែកប្រាក់សោធន
៤. សិក្សាសមិទ្ធិលទ្ធភាពដាក់ឱ្យដំណើរការរបបសន្តិសុខសង្គមផ្នែកនិកម្មភាពការងារ។

តម្លៃស្នូល និងគោលការណ៍មគ្គុទ្ទេសក៍ តម្លាភាព គណនេយ្យភាព សុចរិតភាព និងការគោរពវិន័យក្រមសីលធម៌ និងជំនាញវិជ្ជាជីវៈ សង្គតិភាព និងសាមគ្គីភាព ប្រសិទ្ធភាព និងប្រសិទ្ធផល នវានុវត្តន៍ និងការផ្តួចផ្តើមគំនិតស្វែងរក។

## ៣.១.៣ រចនាសម្ព័ន្ធគ្រប់គ្រង នៃបេឡាជាតិសន្តិសុខសង្គម

### ក. រចនាសម្ព័ន្ធគ្រប់គ្រង




II

### ខ. តួនាទីគណគ្រប់គ្រង

របបសន្តិសុខសង្គម ជាស្ថាប័នប្រតិបត្តិករតែមួយគត់ដែលធ្វើប្រតិបត្តិការរបបសន្តិសុខសង្គម ផ្នែកប្រាក់សោធន ផ្នែកថែទាំសុខភាព ផ្នែកហានិភ័យការងារ និងផ្នែកនិកម្មភាពការងារ និងជាគ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលត្រូវបានបង្កើតឡើងដោយព្រះរាជក្រឹត្យព្រមទាំងជានីតិបុគ្គលនៃនីតិសាធារណៈ និងមានថវិកាស្វយ័ត។ បេឡាជាតិសន្តិសុខសង្គមស្ថិតក្រោមអាណាព្យាបាលបច្ចេកទេសនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងស្ថិតក្រោមអាណាព្យាបាលហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ របបសន្តិសុខសង្គមមានភារកិច្ចដូចខាងក្រោម៖

១. គ្រប់គ្រងនិងចាត់ចែងផ្នែកទាំងអស់នៃរបបសន្តិសុខសង្គម។

២. ជានាផ្តល់តាវកាលិកសន្តិសុខសង្គមសម្រាប់សមាជិករបបសន្តិសុខសង្គមក្នុងគោលដៅជួយសម្រាលការលំបាកក្នុងជីវភាពនៅពេលជួបប្រទះហានិភ័យដាយថាហេតុនានា ជាអាទិ៍ ជរាភាព ទុព្វលភាព មរណភាព ហានិភ័យការងារ និកម្មភាពការងារ មាតុភាព ជំងឺ ឬគ្រោះថ្នាក់ ព្រមទាំងយថាភាពដទៃផ្សេងទៀត។

៣. ប្រមូល និងគ្រប់គ្រងភាគទានរបបសន្តិសុខសង្គមនៃផ្នែកនីមួយៗ ព្រមទាំងប្រភពចំណូលដទៃផ្សេងទៀត។

៤.ចុះបញ្ជីនិងគ្រប់គ្រងលេខសម្គាល់សមាជិកបេឡាជាតិសន្តិសុខសង្គម។

៥. ត្រួតពិនិត្យការអនុវត្តបទប្បញ្ញត្តិនៃច្បាប់ស្តីពីរបបសន្តិសុខសង្គម ដោយសហគ្រាស គ្រឹះស្ថានឬអង្គភាពពាក់ព័ន្ធដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់បេឡាជាតិសន្តិសុខសង្គម។

៦. អប់រំ ផ្សព្វផ្សាយ និងត្រួតពិនិត្យការអនុវត្តន៍វិធានការបង្ការហានិភ័យការងារ និងបង្ការសុខភាពសម្រាប់សមាជិកបេឡាជាតិសន្តិសុខសង្គម។

៧.សិក្សាស្រាវជ្រាវនិងអង្កេតហានិភ័យការងារ។

៨.សិក្សាស្រាវជ្រាវនិងរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីការកំណត់ប្រភេទជំងឺវិជ្ជាជីវៈ។

៩.ចុះកិច្ចព្រមព្រៀងនិងត្រួតពិនិត្យការអនុវត្តន៍កិច្ចព្រមព្រៀងជាមួយមូលដ្ឋានសុខាភិបាល។

១០.សិក្សាវិភាគនិងវាយតម្លៃហិរញ្ញវត្ថុលើផ្នែកនីមួយៗនៃរបបសន្តិសុខសង្គម។

១១. អនុវត្តសកម្មភាពពាក់ព័ន្ធនឹងសុខភាព សង្គមដែលជាអត្ថប្រយោជន៍នៃសមាជិកបេឡាជាតិសន្តិសុខសង្គម។

១២. ចាត់ចែងនិងគ្រប់គ្រងការវិនិយោគមូលនិធិសន្តិសុខសង្គម។

## ៣.២ អត្ថប្រយោជន៍ដែលទទួលបានពីប្រាក់នៃបេឡាជាតិសន្តិសុខសង្គម

### ៣.២.១ ដំណើរការក្នុងការទទួលបានពីប្រាក់សោធន

របបសន្តិសុខសង្គមផ្នែកប្រាក់សោធន គឺប្រៀបបានទៅនឹងផែនការសន្សំប្រាក់រយៈពេលវែងដោយមិនដឹងខ្លួន ដែលទទួលបានផលតបស្នងត្រលប់មកវិញនៅពេលដែលសាមីខ្លួនបាត់បង់សមត្ថភាពការងារ ឬចូលដល់វ័យចាស់ជរាចាប់ពី អាយុ៦០ឆ្នាំឡើងទៅ។ ផ្នែកប្រាក់សោធន គឺជាប្រព័ន្ធសន្តិសុខសង្គមមានលក្ខណៈជាសកល ដែលអាចនាំឱ្យប្រទេសកម្ពុជាមានការផ្សាភ្ជាប់ទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយអង្គភាពទទួលបន្ទុកប្រាក់សោធន នៅតាមបណ្តាប្រទេសលើពិភពលោក ដើម្បីធ្វើសកលភាវូបនីយកម្មរបបសន្តិសុខសង្គមផ្នែកប្រាក់សោធននេះ។ តាមរយៈការដាក់ឱ្យដំណើរការរបបសន្តិសុខសង្គម ផ្នែកប្រាក់សោធន គឺជាការធានាបាននូវសង្គតិភាពរវាងបុគ្គលត្រូវគាំពារទាំងបីក្រុម រួមមានបុគ្គលស្ថិតនៅក្នុងវិស័យសាធារណៈ បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ដោយរួមបញ្ចូលទាំងបុគ្គលិកធ្វើការតាមផ្លូវអាកាសនិងនាវាសមុទ្រ ព្រមទាំងអ្នកបម្រើក្នុងផ្ទះ និងបុគ្គលស្វ័យនិយោជន៍ ដោយផ្នែកនេះត្រូវបានបែងចែកចេញជា ២ គឺផ្នែកប្រាក់សោធនតាមរបបភាគទានជាកាតព្វកិច្ច និងតាមរបបភាគទានដោយស្ម័គ្រចិត្ត។ តាវកាលិកផ្នែកប្រាក់សោធនរួមមាន សោធនជរាភាព សោធនទុព្វលភាព សោធនឧត្តរជីវី និងវិភាជន៍បូជាសព។

### ៣.២.២ ការវាយតម្លៃប្រាក់សោធន

តាមរយៈគម្រោងផែនការពាក់ព័ន្ធនឹងការវាយតម្លៃហានិភ័យហិរញ្ញវត្ថុ និងការវិនិយោគនេះ ឯកឧត្តមអគ្គនាយកបេឡាជាតិសន្តិសុខសង្គមបានបញ្ជាក់ឱ្យដឹងថា៖ កន្លងមកបេឡាជាតិសន្តិសុខសង្គមបានទទួលវគ្គបណ្តុះបណ្តាលតាមប្រព័ន្ធអនឡាញចំនួន ៣ដង ក្នុងឆ្នាំ២០២១ ពីអង្គការអន្តរជាតិខាងការងារពាក់ព័ន្ធទៅនឹងផ្នែកវិនិយោគមូលនិធិសន្តិសុខសង្គម និងការគណនាវាយតម្លៃហានិភ័យហិរញ្ញវត្ថុ ការគ្រប់គ្រង

ទិន្នន័យ សម្រាប់ការវាយតម្លៃហានិភ័យហិរញ្ញវត្ថុ និងផែនការយុទ្ធសាស្ត្រវិនិយោគ ធៀបនឹងការគណនាវាយតម្លៃហានិភ័យហិរញ្ញវត្ថុធៀបនឹងការគ្រប់គ្រងហិរញ្ញវត្ថុផងដែរ។

គួរបញ្ជាក់ថា៖ ក្នុងកិច្ចសហការដ៏ល្អជាមួយបេឡាជាតិសន្តិសុខសង្គមកន្លងមក និងយោងតាមស្មារតីនៃអង្គប្រជុំខាងលើ អង្គការអន្តរជាតិខាងការងារ បានស្នើសុំពិភាក្សាបន្ថែមជាមួយក្រុមការងារ នឹងឯកឧត្តមអគ្គនាយក ដើម្បីស្វែងយល់នូវការគាំទ្របេឡាជាតិសន្តិសុខសង្គមត្រូវការពីអង្គការអន្តរជាតិខាងការងារនិងស្នើសុំការឯកភាពពាក់ព័ន្ធនឹងផែនការការងារខាងលើ និងផែនការការងារលម្អិតសម្រាប់ការបណ្តុះបណ្តាលពាក់ព័ន្ធ នឹងការវាយតម្លៃហានិភ័យហិរញ្ញវត្ថុមុនពេលឈានដល់ការអនុវត្តន៍ផែនការការងារខាងលើនេះ។ ឆ្លៀតក្នុងឱកាសជាមួយគ្នានេះដែរ ឯកឧត្តមអគ្គនាយកបេឡាជាតិសន្តិសុខសង្គមក៏បានស្នើសុំអង្គការអន្តរជាតិខាងការងារក្នុងការផ្តល់អ្នកប្រឹក្សាយោបល់ ដើម្បីជួយដល់ដំណើរការរៀបចំផែនការសកម្មភាពលម្អិតនៃការអភិវឌ្ឍន៍ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានថ្មីនៃគម្រោងទំនើបភាវូបនីយកម្មដំណាក់កាលទី២ របស់បេឡាជាតិសន្តិសុខសង្គមផងដែរ។

សូមបញ្ជាក់ជូនថា៖ កិច្ចប្រជុំខាងលើប្រព្រឹត្តទៅនៅព្រឹកថ្ងៃចន្ទ ទី១៤ ខែកុម្ភៈ ឆ្នាំ២០២២ នៅសាលប្រជុំធំ ស្នាក់ការកណ្តាល រាជធានីភ្នំពេញ ដោយមានការចូលរួមពីទ្វេភាគីរវាងតំណាងអង្គការអន្តរជាតិខាងការងារ និងថ្នាក់ដឹកនាំ មន្ត្រីជំនាញនៃបេឡាជាតិសន្តិសុខសង្គមសរុបប្រមាណជាង ១០រូប។

### ៣.២.៣ តួនាទី និងភារៈប្រាក់សោធននៃបេឡាជាតិសន្តិសុខសង្គម

ប្រាក់សោធននៃបេឡាជាតិសន្តិសុខសង្គម គឺជាប្រព័ន្ធដែលផ្តល់ការពារផ្នែកហិរញ្ញវត្ថុ និងសង្គម ដល់បុគ្គលនិងគ្រួសារ ប្រសិនបើពួកគេចាញ់ការងារ មានជំងឺ ឬមានការបាត់បង់សមត្ថភាព ក៏ដូចជា សម្រាប់អ្នកចាស់។ ប្រព័ន្ធនេះមានតួនាទី និងភារៈសំខាន់ក្នុងការគាំទ្រផ្នែកហិរញ្ញវត្ថុ និងការរក្សាសន្តិសុខសង្គមសម្រាប់បុគ្គល និងគ្រួសារជាពិសេសនៅពេលមានការប្រែប្រួលក្នុងជីវិត។ តួនាទីនៃប្រាក់សោធននៃបេឡាជាតិសន្តិសុខសង្គម៖

- **ការផ្តល់ការពារប្រចាំថ្ងៃ៖** ប្រព័ន្ធសន្តិសុខសង្គមផ្តល់ប្រាក់សោធនសម្រាប់បុគ្គលដែលមានការបាត់បង់ការងារ(ជាទូទៅសម្រាប់អ្នកពិនិត្យការងារ) និងការអតិផរណានៃសេវាកម្មសង្គមផ្សេងៗហើយក៏ជួយក្រុមគ្រួសារដែលពឹងផ្អែកលើបុគ្គលដែលមានការបាត់បង់សមត្ថភាព។
- **ការពារផ្នែកសុខភាព៖** ប្រព័ន្ធនេះផ្តល់ជំនួយសុខភាពសម្រាប់បុគ្គលដែលមានជំងឺ ឬមានការបាត់បង់សមត្ថភាព បេឡាសន្តិសុខសង្គមផ្តល់ជំនួយសម្រាប់ការព្យាបាល និងសម្រួលដល់ការរស់នៅក្នុងមួយកម្រិតទៀត។
- **ការប្រកួតប្រជែងអាយុចាស់៖** ប្រព័ន្ធប្រាក់សោធននេះផ្តល់ការជំនួយសម្រាប់អ្នកចាស់ដែលមិនអាចធ្វើការបាន ឬក៏អ្នកដែលបានចូលក្នុងវ័យចំណាស់ និងត្រូវការពិចារណា សម្រាប់ការជួយដល់ការរស់នៅ។
- **ការចូលរួមក្នុងសេដ្ឋកិច្ចសង្គម៖** ប្រព័ន្ធនេះ អាចបង្ហាញអំពីការចូលរួមសកម្មភាពសង្គមក្នុងសេដ្ឋកិច្ចដោយការប្រើប្រាស់ប្រាក់សោធននៅតាមការចំណាយ ឬការបង់ចំណាយក្នុងការសម្រេចចិត្តនៅក្នុងប្រព័ន្ធ។
- **ការពង្រឹងនិងការអភិវឌ្ឍន៍៖** ប្រព័ន្ធប្រាក់សោធនសង្គមជួយសម្រួលក្នុងការអភិវឌ្ឍន៍ និងការពង្រឹងភាពសន្តិសុខសង្គមដល់គ្រួសារ និងបុគ្គល ដោយផ្តល់ភាពស្មោះត្រង់ និងកាន់តែមានសុខុមាលភាពបុគ្គលឬគ្រួសារ។

## ៣.៣ នីតិវិធីដើម្បីទទួលបានពីប្រាក់សោធននៃបេឡាជាតិសន្តិសុខសង្គម

### ៣.៣.១ នីតិវិធីនៃបេឡាជាតិសន្តិសុខសង្គមបុគ្គលដែលមានសិទ្ធទទួលបានប្រាក់សោធនអំឡុងពេលបំពេញការងារ

របបសន្តិសុខសង្គម ផ្នែកហានិភ័យការងារត្រូវបានដាក់ឱ្យអនុវត្តនៅខែវិច្ឆិកា ឆ្នាំ២០០៨ដោយអនុលោមតាមព្រះរាជក្រមលេខ នស/រកម/០៩០២/០១៨ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០២ ស្តីពីការប្រកាសឱ្យប្រើ ច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ដើម្បីគាំពារដល់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ និងមានវិសាលភាពអនុវត្តជាជំណាក់កាលទៅតាមកត្តាភូមិសាស្ត្រ ព្រមទាំងបានពង្រីកវិសាលភាព ទូទាំងប្រទេសនៅក្នុងឆ្នាំ២០០៩។ ដោយទទួលបានជោគជ័យគួរជាទីមោទនភាពនាពេលកន្លងមក រាជរដ្ឋាភិបាល បានផ្តល់សេចក្តីទុកចិត្តលើ បេឡាជាតិសន្តិសុខសង្គម ក្នុងការអនុវត្តនូវតួនាទី និងភារកិច្ចជាប្រតិបត្តិករសន្តិសុខសង្គម។ ទើបដាក់ឱ្យដំណើរការ របបសន្តិសុខសង្គមសម្រាប់បុគ្គលនៃវិស័យសាធារណៈដោយអនុលោមតាមព្រះរាជក្រឹត្យលេខ នស/រកត/០២១៧/០៧៨ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការបង្កើតរបបសន្តិសុខសង្គមផ្នែក ហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈ និងផ្នែកថែទាំសុខភាព សម្រាប់មន្ត្រីសាធារណៈអតីតមន្ត្រីរាជការ និងអតីតយុទ្ធជន និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធមួយចំនួនទៀត ដែលបង្ហាញឱ្យឃើញពីការយកចិត្តទុកដាក់ខ្ពស់របស់រាជរដ្ឋាភិបាល លើសុវត្ថិភាពការងារ សង្គតិភាពរបបសន្តិសុខសង្គម ការធានានូវសន្តិសុខប្រាក់ចំណូល និងការពារមិនឱ្យប្រជាពលរដ្ឋធ្លាក់ចូលក្នុងស្ថានភាពក្រីក្រ។

**ក. បុគ្គលស្ម័គ្រចិត្ត**

បុគ្គលទាំងឡាយណាដែលស្ថិតនៅក្រោមបទបញ្ញត្តិនៃច្បាប់ស្តីពីការងារដោយរួមបញ្ចូលទាំងបុគ្គលិកធ្វើការតាមផ្លូវអាកាស និងនាវាសមុទ្រ ព្រមទាំងអ្នកបម្រើក្នុងផ្ទះ អាចចូលរួមក្នុងផ្នែកប្រាក់សោធនតាមរបបភាគទានដោយស្ម័គ្រចិត្ត ក្នុងលក្ខខណ្ឌដូចខាងក្រោម ÷

- បាត់បង់ការងារដែលមានប្រាក់ឈ្នួលមុនអាយុ ៦០ ឆ្នាំ
- មានលទ្ធភាពបង់ភាគទានបន្ត។

បុគ្គលទាំងឡាយណាដែលស្ថិតនៅក្រោមបទបញ្ញត្តិនៃច្បាប់ស្តីពីការងារ ដោយរួមបញ្ចូលទាំងបុគ្គលិកធ្វើការតាមផ្លូវអាកាស និងនាវាសមុទ្រ ព្រមទាំងអ្នកបម្រើក្នុងផ្ទះដែលមានអាយុគ្រប់ ៦០ ឆ្នាំនិងមានបំណងបង់ភាគទានបន្ត ដើម្បីទទួលបានសោធនជរាភាពខ្ពស់ជាងសោធនជរាភាពជាក់ស្តែង ដែលសាមីខ្លួនត្រូវទទួលបានតាមរបបភាគទានជាកាតព្វកិច្ច អាចចូលរួមក្នុងផ្នែកប្រាក់សោធនតាមរបបភាគទានដោយស្ម័គ្រចិត្តបាន។ ក្នុងករណីនេះសោធនជរាភាពត្រូវបើកផ្តល់តាមការបរិច្ឆេទដាក់លាក់ ដែលសាមីខ្លួនអស់លទ្ធភាពចូលរួមក្នុងផ្នែកនេះ។ អ្នកដែលមានប្រាក់ចំណូលខ្ពស់ជាងប្រាក់ឈ្នួលពិតានដែលសាមីជនជាប់កាតព្វកិច្ចក្នុងរបបភាគទានជាកាតព្វកិច្ច អាចចូលរួមក្នុងផ្នែកប្រាក់សោធនតាមរបបភាគទានដោយស្ម័គ្រចិត្តបាន។ ការបង់ភាគទានក្នុងផ្នែកនេះត្រូវអនុវត្តចំពោះតែចំណែកនៃប្រាក់ឈ្នួល ដែលខ្ពស់ជាងប្រាក់ឈ្នួលតាមប្រព័ន្ធហិរញ្ញប្បទានពេញលេញ។ ការបង់ភាគទានផ្នែកប្រាក់សោធនតាមរបបភាគទានដោយស្ម័គ្រចិត្តជាបន្ទុកផ្ទាល់របស់សាមីជន។

**ខ. ដៃគូសហការបេឡាជាតិសន្តិសុខសង្គម**

ការអនុវត្តការងារក្នុងមុខរបរណាមួយជាកំណត់ ពោលគឺរោគឬជំងឺដែលមានទំនាក់ទំនងផ្ទាល់ជាមួយនឹងកត្តានានានៃការងារមានជាអាទិ៍ កំឡុងពេលធ្វើការងារ កន្លែងធ្វើការងាររបៀបធ្វើការងារ សារធាតុឬវត្ថុធាតុប្រើប្រាស់ក្នុងផលិតកម្ម បរិយាកាសនៃកន្លែងធ្វើការជាដើម ដែលអាចធ្វើឱ្យកើតរោគឬជំងឺ ទោះបីក្នុងកំឡុងពេលដែលសាមីជនកំពុងបំពេញការងារឬមុខរបរ ឬក្រោយកំឡុងពេលដែលលែងបំពេញការងារឬមុខរបរទាំងនោះក្តី។ ដើម្បីអាចដាក់ឯកសារស្នើសុំតាវកាលិក ផ្នែកហានិភ័យការងារជនរងគ្រោះត្រូវជូនដំណឹងជាបន្ទាន់ ទៅនិយោជក ឬអ្នកតំណាងសហគ្រាស គ្រឹះស្ថាន។ ករណីគ្រោះថ្នាក់រហូតដល់បាត់បង់ជីវិត កាតព្វកិច្ចជូនដំណឹងនេះ ត្រូវផ្ទេរទៅសិទ្ធិវន្ត(បុគ្គលទទួលបានសិទ្ធិក្នុងការស្នើសុំតាវកាលិក)។ ក្រោយពីទទួលបានការជូនដំណឹងពីជនរងគ្រោះ និយោជក ឬអ្នកតំណាងសហគ្រាសគ្រឹះស្ថានត្រូវធ្វើលិខិតបញ្ជូនជនរងគ្រោះទៅមូលដ្ឋានសុខាភិបាលដៃគូ បេឡាជាតិសន្តិសុខសង្គម និងធ្វើរបាយការណ៍ហានិភ័យការងារ និងឯកសារជំនួយស្មារតីមក បេឡាជាតិសន្តិសុខសង្គម ដើម្បីអធិការសន្តិសុខសង្គមធ្វើការអង្កេតករណីគ្រោះថ្នាក់។

**៣.៣.២ លក្ខខណ្ឌនៃការប្រើប្រាស់**

លក្ខខណ្ឌនៃការប្រើប្រាស់នីតិវិធីដើម្បីទទួលបានប្រាក់សោធននៃបេឡាជាតិសន្តិសុខសង្គមគឺត្រូវការរកំណត់កាតព្វកិច្ច និងគោលការណ៍ដែលគ្រប់គ្រងដោយអាជ្ញាធរ ជាអ្នកគ្រប់គ្រងបេឡាជាតិសន្តិសុខសង្គម។ ខាងក្រោមនេះគឺជាលក្ខខណ្ឌសំខាន់ៗដែលត្រូវយោងទៅលើការទទួលប្រាក់សោធនៈ

➤ **សិទ្ធិទទួលប្រាក់សោធន**

• ស្ថានភាពការងារ: អ្នកត្រូវតែមានការងារប្រាក់ឬអតីតការងារដែលបានបង់សំណាងសង្គមសន្តិសុខ (បង់ប្រាក់សោធនContribution) ជាថ្មីៗ។

• ការព្យាបាលសុខភាព: ប្រសិនបើអ្នកមានជំងឺ ឬមិនអាចធ្វើការបានដោយសារតែបញ្ហាសុខភាព អ្នកអាចសុំការព្យាបាលសុខភាព ហើយទទួលបានប្រាក់សោធនក្នុងពេលណាមួយ។

អាយុ អ្នកត្រូវតែមានអាយុតិចតួច (ដូចជា ក្រោមអាយុជាចាស់ ឬអាយុចំណាត់ថ្នាក់ផ្សេងៗ)។

• ស្ថានភាពគ្រួសារ: ប្តី ឬ ប្រពន្ធមានសំបុត្រអាពាហ៍ពិពាហ៍ ឬ មិនទាន់រៀបអាពាហ៍ពិពាហ៍ ដែលមានកូនអាយុក្រោម ១៨ឆ្នាំ(មានជំងឺពុំរ៉ៃឬ ពិការ)ដែលគ្មានប្រាក់ចំណូល គឺត្រូវបានផ្តល់ជូនមួយជីវិត។

➤ **ការចុះបញ្ជីសម្រាប់ប្រាក់សោធន**

អ្នកត្រូវតែចុះបញ្ជីជាផ្លូវការនៅក្នុងប្រព័ន្ធសង្គមសន្តិសុខរបស់ប្រព័ន្ធបេឡា និងបញ្ជាក់ថាអ្នកមិនមានការងារជាក់ស្តែងឬមិនអាចធ្វើការបាន។ការចុះបញ្ជីនេះគួរត្រូវការតម្រូវការតាមលក្ខខណ្ឌជាក់លាក់ណាមួយដែលអាជ្ញាធរនៅក្នុងប្រព័ន្ធបេឡាមានតាមក្រុមប្រឹក្សា។

➤ **ការទទួលប្រាក់សោធន**

ក្រោមលក្ខខណ្ឌនេះ ប្រាក់សោធនអាចមានការផ្តល់ជូនដល់អ្នកដែលគ្មានការងារ ជាធម្មតាវាត្រូវការត្រួតពិនិត្យនិងដាក់ពាក្យដែលអាចផ្តល់ដល់អ្នកផ្ទាល់។

➤ **ការត្រួតពិនិត្យសិទ្ធិ**

ការចុះបញ្ជីត្រូវតែបានពិនិត្យថាតើអ្នកត្រូវតែទទួលប្រាក់សោធនឬអត់?

### ៣.៣.៣ ការផ្សព្វផ្សាយរបស់បេឡាជាតិសន្តិសុខសង្គម

ការផ្សព្វផ្សាយនៃនីតិវិធីដើម្បីទទួលបានប្រាក់សោធននៃបេឡាជាតិសន្តិសុខសង្គម ត្រូវបានធ្វើឡើងយ៉ាងម៉ត់ចត់ ដើម្បីធានាថាប្រជាជនទាំងអស់ដែលមានសិទ្ធិទទួលបានប្រាក់សោធននោះទទួលបានព័ត៌មាន និងអាចដំណើរការតាមនីតិវិធីបានយ៉ាងសមរម្យ។ វាមានវិធីផ្សព្វផ្សាយជាច្រើនដែលបានប្រើប្រាស់ ដូចជា៖

➢ **ការផ្សព្វផ្សាយតាមប្រព័ន្ធប្រតិបត្តិការ (Official Channels)**

• គេហទំព័រផ្លូវការនៃបេឡាជាតិសន្តិសុខសង្គម: ព័ត៌មានអំពីនីតិវិធីទទួលប្រាក់សោធន ត្រូវបានផ្សព្វផ្សាយតាមគេហទំព័រផ្លូវការរបស់ការិយាល័យ សន្តិសុខសង្គម។ នៅទីនេះ អ្នកអាចស្វែងរកព័ត៌មានទាំងអស់ដែលទាក់ទងនឹងការទទួលប្រាក់សោធន និងការចុះបញ្ជី។

• ប្រព័ន្ធអេឡិចត្រូនិច: ប្រព័ន្ធអេឡិចត្រូនិចផ្សេងៗ ដូចជា ការប្រើប្រាស់អ៊ីមែល ឬសារជាអនុគ្រោះផ្លូវការដើម្បីផ្តល់ព័ត៌មានអំពីការបង្ហោះពាក្យសុំ និងការផ្តល់ប្រាក់។

➢ **ការផ្សព្វផ្សាយតាមការបង្ហាញបែបផែនមុខមាត់ (Public Campaigns)**

ការបោះពុម្ពផ្សាយ: ប្រើប្រាស់ផ្ទាំងផ្សព្វផ្សាយ និងប៊ូតិកូដដែលមានព័ត៌មានលម្អិតអំពីការទទួលប្រាក់សោធន និងនីតិវិធីប្រើប្រាស់។ ការផ្សាយផ្សព្វផ្សាយតាមវិទ្យុ និងទូរទស្សន៍ ផ្សព្វផ្សាយព័ត៌មាន និងការណែនាំដល់ពិភពលោកពីកម្រិតទទួលប្រាក់សោធន តាមការបង្ហោះផ្សាយដោយប្រព័ន្ធវិទ្យុ និងទូរទស្សន៍នៅក្នុងប្រទេស។ ការសម្ភាសន៍នៅក្នុងសាលា និងទីកន្លែងធ្វើការផ្សេងៗ ការបង្ហោះព័ត៌មាននៅក្នុងសាលារៀន ឬទីកន្លែងប្រជុំ ដើម្បីជួយសិក្សា និងចុះបញ្ជីបានយ៉ាងប្រសើរឡើង។

➢ **ការផ្សព្វផ្សាយតាមប្រព័ន្ធសង្គម (Social Media)**

ការប្រើប្រាស់បណ្តាញសង្គមដូចជា Facebook, Instagram, និង Twitter ដើម្បីផ្សព្វផ្សាយព័ត៌មានអំពីប្រាក់សោធននៃសង្គមសន្តិសុខ។ ព័ត៌មាននេះអាចផ្តល់ទៅឱ្យអ្នកប្រើប្រាស់ដែលពុំមានភាពអាចស្វែងរកនូវប្រព័ន្ធផ្សព្វផ្សាយទៀត

➢ **ការបណ្តុះបណ្តាល និងការជួយផ្តល់ការណែនាំ**

ការផ្តល់ការបណ្តុះបណ្តាលសម្រាប់ប្រជាជននិងអ្នកដែលពាក់ព័ន្ធតាមការប្រឹក្សាអំពីការស្នាក់នៅក្នុងសកម្មភាព។ ផ្តល់ជូនសេវាកម្មជួយផ្សព្វផ្សាយនិងបង្រៀនពីវិធីសំរាប់បំពេញការសុំប្រាក់សោធឱ្យមានប្រសិទ្ធភាព។

➢ **ការប្រើប្រាស់ផ្ទាំងការងារចុះបញ្ជី និងអំពីការបណ្តុះបណ្តាល**

នៅក្នុងការបង្ហោះពាក្យសុំ និងបង្ហោះមាតិកានៅក្នុងការបើកទ្វារអាជ្ញាធរនៅតំបន់ ឬវិស័យផ្សេងៗ អ្នកអាចផ្តល់សេចក្តីជូនដល់អ្នកចូលរួមក្នុងកម្មវិធីនោះ។ ការផ្សព្វផ្សាយនេះមានគោលបំណងធានាថាប្រជាជនទាំងអស់ដែលមានសិទ្ធិទទួលបានប្រាក់សោធនត្រូវបានជួយឱ្យដឹង និងអាចដំណើរការតាមនីតិវិធីបានយ៉ាងងាយស្រួល។

### ៣.៣.៤ គម្រោងសមាជិក

គម្រោងសមាជិករបស់បេឡាជាតិសន្តិសុខសង្គម គឺផ្អែកលើរបបសន្តិសុខសង្គមនីមួយៗ ដែលគ្របដណ្តប់លើផ្នែកផ្សេងៗនៃកម្មករនិយោជិត។ ខាងក្រោមនេះជាសេចក្តីសង្ខេបសំខាន់ៗ៖

**១. របបសន្តិសុខសង្គមផ្នែកហានិភ័យការងារ (Work Injury Scheme)**

- សមាជិកភាពកាតព្វកិច្ច: និយោជិតទាំងអស់ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ការងារ ត្រូវតែជាសមាជិក។ និយោជកមានកាតព្វកិច្ចចុះឈ្មោះនិយោជិតរបស់ខ្លួននៅក្នុងរបបនេះ។
- ការគ្របដណ្តប់: គ្របដណ្តប់លើគ្រោះថ្នាក់ការងារ និងជំងឺដែលបណ្តាលមកពីការងារ។

**២. របបសន្តិសុខសង្គមផ្នែកថែទាំសុខភាព (Health Care Scheme)**

- សមាជិកភាពកាតព្វកិច្ច: ដូចគ្នានឹងរបបហានិភ័យការងារ និយោជិតទាំងអស់ដែលស្ថិតនៅក្រោមច្បាប់ការងារ ត្រូវតែជាសមាជិក។
- ការគ្របដណ្តប់: ផ្តល់សេវាថែទាំសុខភាព រួមទាំងការពិនិត្យសុខភាព ការព្យាបាល និងការសម្រាកពេទ្យ។

**៣. របបសន្តិសុខសង្គមផ្នែកសោធននិវត្តន៍ (Pension Scheme)**

- សមាជិកភាពកាតព្វកិច្ច: និយោជិតទាំងអស់ដែលស្ថិតនៅក្រោមច្បាប់ការងារត្រូវតែជាសមាជិក។
- អត្ថប្រយោជន៍: ផ្តល់ប្រាក់សោធននិវត្តន៍នៅពេលចូលនិវត្តន៍ ផ្អែកលើការបង់វិភាគទាន និងលក្ខខណ្ឌផ្សេងៗទៀត។

### ៣.៣.៥ ការផ្សព្វផ្សាយដោយផ្ទាល់

ការផ្សព្វផ្សាយដោយផ្ទាល់របស់បេឡាជាតិសន្តិសុខសង្គម គឺជាផ្នែកសំខាន់មួយក្នុងការផ្តល់ព័ត៌មានដល់ប្រជាជនអំពីសេវាកម្ម និងសិទ្ធិដែលពួកគេទទួលបាននៅក្នុងប្រព័ន្ធសង្គមសន្តិសុខ។ វាជាការអនុវត្តន៍ផ្សព្វផ្សាយដោយប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយ និងប្រព័ន្ធទំនាក់ទំនងផ្ទាល់ដើម្បីធានាថាប្រជាជនទាំងអស់មានការចូលដំណើរការផ្តល់សេវាកម្ម។

**• ការប្រើប្រាស់ប្រព័ន្ធទំនាក់ទំនងផ្ទាល់**

ក្រុមការងារ និងអ្នកជំនាញបេឡាជាតិសន្តិសុខសង្គមអាចផ្តល់ព័ត៌មានឱ្យនានាដោយផ្ទាល់ជាមួយសមាជិកសង្គមតាមរយៈប្រព័ន្ធផ្ទាល់ដូចជា ការជជែកទូរស័ព្ទ ការពិភាក្សាតាមអ៊ីមែល ឬប្រព័ន្ធផ្ទាល់សម្របសម្រួលការទទួលសេវាកម្ម។ ក្រុមការងារផ្សព្វផ្សាយ យើងអាចធ្វើការជជែកផ្ទាល់ជាមួយប្រជាជននៅក្នុងកន្លែងធ្វើការផ្សព្វផ្សាយដោយប្រើប្រាស់ពហុបច្ចេកវិទ្យា ដូចជាការតំឡើងផ្ទាំងផ្សព្វផ្សាយនៅតំបន់សាធារណៈ។

**• ការបង្ហោះព័ត៌មាននៅតំបន់សាធារណៈ**

ការផ្សព្វផ្សាយនៅតាមស្ថានីយ៍ធ្វើការជា ផ្ទាំងផ្សព្វផ្សាយ និងប្លុក ការចេញផ្សាយព័ត៌មានតាមផ្ទាំងផ្សព្វផ្សាយ និងការតំឡើងប៊ូតិកូដផ្សព្វផ្សាយនៅកន្លែងសាធារណៈ ដូចជា ស្ថានីយ៍ ធ្វើការងារ និងទីកន្លែងប្រជុំផ្សេងៗ។

ការអនុម័តជារយៈពេលជាបច្ចេកទេស ការដាក់ជាអត្ថបទថ្មីៗផ្សព្វផ្សាយគឺជាការបង្ហោះព័ត៌មានយ៉ាងផ្ទាល់ដោយប្រើបច្ចេកទេសនៅក្នុងការទទួលបានការការសេវាកម្ម និងបរិយាកាស។

**• ការពិភាក្សាអំពីការបង្ហោះតាមឆានែលផ្សេងៗ**

ការបង្ហោះព័ត៌មានតាមឆានែលប្លុកផ្សព្វផ្សាយ: តាមផ្លូវមុខមាត់ឆានែលផ្សព្វផ្សាយលើបណ្តាញសង្គមដែលមិនត្រឹមតែប្រព្រឹត្តនៅតាមការបង្ហោះបណ្តាញតែប៉ុណ្ណោះ។

**• ការប្រើប្រាស់ប្រព័ន្ធឯកសារសាធារណៈ**

ការចេញផ្សាយដោយសារ ជាឯកសារសហជីព ប្រើប្រាស់ឯកសារសាធារណៈ ឬនយោបាយផ្លូវការជាការពិភាក្សាផ្ទាល់។

**៣.៣.៦ ការផ្សព្វផ្សាយដោយប្រយោល**

ការផ្សព្វផ្សាយដោយប្រយោលនៃបេឡាជាតិសន្តិសុខសង្គម គឺជាការផ្សព្វផ្សាយដែលមានគោលបំណងមួយដែលពាក់ព័ន្ធនឹងការពង្រឹងការយល់ដឹងនិងការចូលរួមរបស់ប្រជាជនក្នុងប្រព័ន្ធសង្គមសន្តិសុខ។ ការផ្សព្វផ្សាយប្រយោលនេះសំដៅទៅលើការផ្តល់អត្ថប្រយោជន៍ដល់សមាជិកដែលមានសិទ្ធិទទួលប្រាក់សោធន ឬសេវាកម្មផ្សេងៗទៀត ដើម្បីធានាថាពួកគេចូលរួមយ៉ាងមានប្រសិទ្ធភាពក្នុងប្រព័ន្ធ និងទទួលបានសេវាកម្មដែលពួកគេបានស្នាក់នៅក្នុងសង្គមសន្តិសុខ។

- **គោលបំណងនៃការផ្សព្វផ្សាយប្រយោល**

ការបង្កើនការយល់ដឹង: ផ្សព្វផ្សាយដើម្បីឱ្យប្រជាជនយល់ដឹងអំពីសេវាកម្មនិងសិទ្ធិដែលពួកគេចូលរួមបានពីបេឡាជាតិសន្តិសុខសង្គម។ វាជារបៀបធ្វើឱ្យប្រជាជនមានការយល់ឃើញច្បាស់អំពីតម្រូវការជាក់លាក់ និងរបៀបដាក់ពាក្យសុំសេវាកម្ម។

ការលើកកម្ពស់ការចូលរួម: ផ្សព្វផ្សាយក្នុងរបៀបដែលជួយបង្ហាញអំពីសារៈសំខាន់នៃការចូលរួមក្នុងប្រព័ន្ធសង្គមសន្តិសុខ និងការពង្រឹងភាពប្រសិទ្ធភាពនៃប្រព័ន្ធនេះ។

- **វិធីសាស្ត្រនៃការផ្សព្វផ្សាយប្រយោល**

ការបង្ហោះតាមប្រព័ន្ធផ្សព្វផ្សាយផ្សេងៗ: ប្រើប្រាស់កំណត់ហេតុនៅក្នុងប្រព័ន្ធផ្សព្វផ្សាយផ្សេងៗដូចជា សារព័ត៌មាន ការបង្ហោះតាមវិទ្យុ ទូរទស្សន៍ និងបណ្តាញសង្គមដើម្បីផ្តល់ព័ត៌មាន។

ការអភិវឌ្ឍន៍កម្មវិធីចំណេះដឹង: ការរៀបចំកម្មវិធីបណ្តុះបណ្តាល និងការបង្ហោះព័ត៌មានពីរៀបរាប់បែបផែនសេវាកម្មសង្គមសន្តិសុខនិងអត្ថប្រយោជន៍របស់វា។

- **ប្រយោលនៃការផ្សព្វផ្សាយ**

ការបង្ហាញព័ត៌មានជាក់ស្តែង: ការផ្សព្វផ្សាយដែលផ្តោតលើការបង្ហាញព័ត៌មានដែលត្រូវការ ដូចជាការស្នាក់នៅក្នុងប្រព័ន្ធសង្គមសន្តិសុខ និងការចូលរួមនៅក្នុងគម្រោងសេវាកម្ម។

- **ការតាមដាននិងវាយតម្លៃការផ្សព្វផ្សាយ**

ការប្រមូលព័ត៌មានវិញ បន្ទាប់ពីការផ្សព្វផ្សាយ ប្រព័ន្ធសង្គមសន្តិសុខត្រូវតែវាយតម្លៃលើប្រសិទ្ធភាព និងចំណុចដែលត្រូវប្រើប្រាស់សម្រាប់ការកែលម្អបន្តទៀត។ ដើម្បីជួយសម្រួលការទទួលសេវាកម្មសង្គមសន្តិសុខ និងធានាថាប្រជាជនទទួលបានព័ត៌មានត្រឹមត្រូវ និងមានការចូលរួមយ៉ាងមានប្រសិទ្ធភាពក្នុងប្រព័ន្ធ។

# ជំពូកទី៤
# ការវិភាគចំណុចខ្លាំងនិង ចំណុចខ្សោយ

បន្ទាប់ពីបានធ្វើការសិក្សាស្រាវជ្រាវ ទៅលើអត្ថប្រយោជន៍ដែលទទួលបានពីប្រាក់សោធននៃបេឡាជាតិសន្តិសុខសង្គមរួចមកហើយ ក្រុមរបស់នាងខ្ញុំបានសង្កេតឃើញថា មានចំណុចខ្លាំង និងចំណុចខ្សោយមួយចំនួនដែលកើតមានឡើងនៅក្នុងប្រព័ន្ធផ្ទៃក្នុងរបស់បេឡាជាតិសន្តិសុខសង្គម។ ការធ្វើការវិភាគទៅលើចំណុចខ្លាំង និងចំណុចខ្សោយរបស់បេឡាជាតិសន្តិសុខសង្គម គឺពិតជាមានសារៈសំខាន់ណាស់ក្នុងការវាយតម្លៃពីដំណើរការ និងសកម្មភាពរបស់បេឡាជាតិសន្តិសុខសង្គមដើម្បីឱ្យបេឡាជាតិសន្តិសុខសង្គមកាន់តែមានការអភិវឌ្ឍន៍ និងកាន់តែរីកចម្រើនទៅថ្ងៃខាងមុខបន្តទៀត។ ការវិភាគទៅលើចំណុចខ្លាំង និងចំណុចខ្សោយរបស់បេឡាជាតិសន្តិសុខសង្គមរួមមានដូចខាងក្រោម៖

## ៤.១ ការវិភាគចំណុចខ្លាំង

បេឡាជាតិសន្តិសុខសង្គមបានផ្តល់នៅអត្ថប្រយោជន៍ជាច្រើនដល់ប្រជាពលរដ្ឋ និងសង្គម រួមទាំងបានជួយលើកស្ទួយ លើវិស័យរដ្ឋ និងឯកជនឱ្យកាន់តែមានភាពរីកចម្រើនផងដែរ។ ខាងក្រោមនេះជាចំណុចខ្លាំងនៃប្រាក់សោធននៃបេឡាជាតិសន្តិសុខសង្គមមានដូចជា៖

- ធានាកម្រិតជីវភាពគ្រួសាររបស់បុគ្គលនៃវិស័យសាធារណៈ បុគ្គលទាំងឡាយ ដែលស្ថិតក្រោមបទប្បញ្ញាតិនៃច្បាប់ស្តីពីការងារ ដោយរួមបញ្ចូលទាំងបុគ្គលិកធ្វើការគ្រប់ផ្នែក
- បុគ្គលដែលជាសមាជិកបេឡាជាតិសន្តិសុខសង្គមមានក្តីសង្ឃឹមលើការងារទាំងក្នុងវិស័យសាធាណៈ និងវិស័យនិយោជន៍
- លើកស្ទួយសមធម៌ សាមគ្គីធម៌និងយុត្តិធម៌ក្នុងសង្គមតាមរយៈការរំលែកហានិភ័យ
- ចូលរួមចំណែកនិងលើកស្ទួយកម្មវិធីកំណែទម្រង់នយោបាយរបស់រដ្ឋាភិបាលក្នុងការកាត់បន្ថយភាពក្រីក្រ
- បញ្ជាក់ឱ្យឃើញនូវការយកចិត្តទុកដាក់ពីប្រមុខរដ្ឋាភិបាលក្នុងការធានានិរន្តរភាពដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋទាំងបច្ចុប្បន្ននិងនាពេលអនាគត
- ចូលរួមការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ តាមរយៈការវិនិយោគថវិការដែលនៅសល់ពីការប្រើប្រាស់សម្រាប់តាវកាលិក
- អនុវត្តសកម្មភាព ពាក់ព័ន្ធនឹងប្រាក់សោធន និងសង្គមដែលពាក់ព័ន្ធនឹងអត្ថប្រយោជន៍នៃសមាជិកបេឡាជាតិសន្តិសុខសង្គម

## ៤.២ ការវិភាគចំណុចខ្សោយ

ក្រៅពីចំណុចខ្លាំងនៃប្រាក់សោធននៃបេឡាជាតិសន្តិសុខសង្គមក្នុងនោះក៏មានបង្កប់នូវចំណុខ្សោយមួយចំនួនផងដែរ៖

- មានការរិះគន់ច្រើនអំពីសេវាកម្ម ដូចជា ពេលរងចាំយូរ
- មិនអាចបង្ខំឱ្យអាជីវកម្មខ្នាតតូច ឬនៅតំបន់ជនបទ អនុវត្តបានពេញលេញនូវច្បាប់ទេ
- ការចុះបញ្ជីមិនគ្រប់គ្រាន់ និងការទទួលអត្ថប្រយោជន៍នៅមានកម្រិតទាប

- ការអនុវត្តន៍មិនល្អ ចំពោះការត្រួតពិនិត្យមិនទាន់ត្រឹមត្រូវពីម្ចាស់កម្មករ និងសហគ្រាស
- ការគ្របដណ្ដប់នៅមានកម្រិតនៅឡើយពីព្រោះសហគ្រាសមួយចំនួនមិនបានដឹងអំពីតម្រូវការ និងនីតិវិធីនៃការចុះឈ្មោះទៅក្នុងបេឡាជាតិសន្តិសុខសង្គម
- ប្រាក់ឈ្នួលជាមធ្យមនៅកម្ពុជាមានកម្រិតទាប ដែលបណ្ដាលឱ្យវិភាគទានចូលក្នុងប្រព័ន្ធសោធននិវត្តន៍មានកម្រិតទាបផងដែរ
- ប្រជាជនកម្ពុជាជាច្រើនប្រហែលជាមិនយល់ច្បាស់អំពីប្រយោជន៍នៃប្រព័ន្ធសោធននិវត្តន៍ ឬរបៀបចូលរួមនោះទេ។

# ជំពូកទី៥
# សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

## ៥.១ សេចក្តីសន្និដ្ឋាន

តាមលទ្ធផលនៃការស្រាវជ្រាវតាំងពីចំណុចដំបូងមកយើងអាចសន្និដ្ឋានបានថាអត្ថប្រយោជន៍ដែលទទួលបានពីប្រាក់សោធននៃបេឡាសន្តិសុខសង្គម បានផ្តល់នូវអត្ថប្រយោជន៍ជាច្រើនយ៉ាងគួរឱ្យកត់សម្គាល់ជូនដល់ប្រជាពលរដ្ឋទាំងប្រាក់ជំនួយដែលផ្តល់ឱ្យកម្មករនិយោជិត មន្ត្រីរាជការក្នុងវិស័យសាធារណៈ ព្រមទាំងអតីតមន្ត្រីរាជការ និងអតីតយុទ្ធជនដែលជួយសម្របសម្រួលដល់ជីវភាពគ្រួសារកំពុងសម្រាកព្យាបាលជម្ងឺដើម្បីទទួលបានការការពារពេលមានគ្រោះថ្នាក់ការងារ។

លើសពីនេះ រហូតមកដល់បច្ចុប្បន្នបេឡាសុន្តិសុខសង្គមក៏បន្តគ្របដណ្តប់លើវិសាលយ៉ាងធំទូលាយនៅក្នុងប្រទេសកម្ពុជាដែលបញ្ជាក់បានថា ការវិវត្តន៍របស់ប្រព័ន្ធបេឡាសុន្តិសុខសង្គមនៅកម្ពុជាបានបន្តជួយសម្របសម្រួលជាច្រើនដល់និយោជកព្រមទាំងផ្តល់អត្ថប្រយោជន៍ជាសាច់ប្រាក់ច្រើនដល់សមាជិកឬអ្នកក្នុងបន្ទុក។ បន្ថែមពីនេះទៅទៀតរាជរដ្ឋាភិបាលក៏បានរួមបញ្ចូលទៅនិងការជួយសម្រាលការលំបាកក្នុងជីវភាពរបស់ប្រជាពលរដ្ឋដោយធានានូវសន្តិសុខសង្គម ជួយទប់ស្កាត់ហានិភ័យជាច្រើនដែលអាចប៉ះពាល់ដល់សេដ្ឋកិច្ចគ្រួសារ រួមចំណែក កាត់បន្ថយភាពក្រីក្រ ដែលប្រជាពលរដ្ឋបានជួបប្រទះនៅក្នុងជីវិតប្រចាំថ្ងៃផងដែរ។ មិនតែប៉ុណ្ណោះប៉ុន្មានឆ្នាំចុងក្រោយមកនេះបេឡាជាតិសន្តិសុខសង្គមបានវិវត្តន៍ខ្លួនឥតឈប់ឈរបង្ហាញខ្លួនយ៉ាងសម្បើមលើរបបសន្តិសុខសង្គមនៅកម្ពុជាដោយបានក្តាប់ដណ្តប់លើរបបចំនួនពីរ គឺរបបហានិភ័យការងារ និងរបបថែសុខភាពហើយនាពេលខាងមុខនេះ នឹងដាក់សំណើរនៅរបបសោធន នៅក្នុងវិស័យឯកជននិងមន្ត្រីរាជការសាធារណៈ។ទោះបីក្នុងរបបប្រល័យពូជសាសន៍របបនេះ ត្រូវបានបំបាត់ចោលទាំងស្រុងនិងបានបំផ្លាញ ក៏នាពេលបច្ចុប្បន្នដោយបានគាំទ្រពីរដ្ឋាភិបាលបានធ្វើការវិសោធនកម្មច្បាប់ថ្មីម្តងទៀតផងដែរ។

## ៥.២ ការផ្តល់អនុសាសន៍

បើយោងតាមការរៀបរាប់ខាងលើបានសេចក្តីលម្អិតអំពីលទ្ធផលនៃការស្រាវជ្រាវរបស់ក្រុមយើងខ្ញុំដែលស្តីពី អត្ថប្រយោជន៍ដែលទទួលបានពីប្រាក់សោធននៃបេឡាជាតិសន្តិសុខសង្គមក្រុមយើងខ្ញុំក៏បានស្វែងយល់ និងរកឃើញនូវចំណុចខ្វះខាតបន្តិចបន្តួចដើម្បីចូលរួមចំណែកក្នុងការផ្តល់យោបល់ និងសំណូមពរមួយចំនួនដែលនៅក្នុងនោះមានដូចជា៖

- ពង្រឹងការអនុវត្តន៍ច្បាប់ពាក់ព័ន្ធទៅនឹងរបបបេឡាជាតិសន្តិសុខសង្គមឱ្យកាន់តែមានប្រសិទ្ធភាព
- គួរតែមានវិធានការណ៍នានា រឹតបន្តឹងចំពោះមន្ត្រី និងបុគ្គលិកដែលមិនគោរពគោលការណ៍ និងបទបញ្ជាផ្ទៃក្នុងរបស់អង្គភាព
- ចុះពន្យល់ណែនាំ ដល់គ្រឹះស្ថានសហគ្រាស ដែលមិនទាន់យល់ពីការទទួលអត្ថប្រយោជន៍ដែលខ្លួនទទួលបានពីបេឡាជាតិសន្តិសុខសង្គម
- ផ្តល់សេវាសុខាភិបាល និងអត្ថប្រយោជន៍ដល់សមាជិកឱ្យបានទាន់ពេលវេលា

- រឹតបន្តឹងមូលដ្ឋានសុខាភិបាល ដែលបានចុះកិច្ចព្រមព្រៀងជាមួយ បេឡាសន្តិសុខសង្គម ដើម្បីផ្តល់សេវាកម្មឱ្យកាន់តែមានប្រសិទ្ធិភាព។

# ឯកសារយោង


១. បេឡាជាតិសន្តិសុខសង្គម. (2020). *របាយការណ៍សកម្មភាពប្រចាំឆ្នាំ២០១៩.* ភ្នំពេញបេឡាជាតិសន្តិសុខសង្គម. Retrieved from https://www.nssf.gov.kh/

២. ព្រះរាជក្រឹត្យលេខ16អនក្រ.បក .(2007). អំពីការបង្កើតគ្រឹះស្ថានសាធារណៈបេឡាជាតិសន្តិសុខ សង្គម. រាជរដ្ឋាភិបាលកម្ពុជា.

៣. ច្បាប់ស្តីពីរបបសន្តិសុខសង្គម. (2019). សេចក្តីវិសោធនកម្មច្បាប់ស្តីពីសន្តិសុខសង្គម. ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ.

៤. ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ. (2023). របាយការណ៍សេដ្ឋកិច្ច និងហិរញ្ញវត្ថុប្រចាំឆ្នាំ. ភ្នំពេញ: MEF.

៥. សមាគមការងារនៃកម្ពុជា(CAMFEBA). (2022). ស្ថានភាពសិទ្ធិនិយោជិត និងសន្តិសុខសង្គមក្នុងវិស័យឯកជន. ភ្នំពេញ.

៦. International Labour Organization (ILO). (2021). Social Protection in Cambodia: Current progress and future directions. Geneva: ILO.

៧. World Bank. (2022). Cambodia Economic Update: Strengthening Economic Recovery and Social Protection. Washington, DC: World Bank Group.

៨. ច្បាប់ស្តីពីរបបសន្តិសុខសង្គម (Law on Social Security Schemes) ច្បាប់នេះបែងចែកនូវការផ្តល់សេវាសន្តិសុខសង្គម ជាពីរផ្នែកគឺផ្នែកប្រាក់សោធន និងសេវាសុខាភិបាល សម្រាប់បុគ្គលស្ថិតក្នុងវិស័យសាធារណៈ និងឯកជន។ Retrieved from http://nssf.gov.kh

៩. អនុក្រឹត្យលេខ 16 អនក្រ.បក ចុះថ្ងៃទី ២ មីនា ២០០៧ អនុក្រឹត្យនេះគឺជាច្បាប់ស្ថាបនាបេឡាជាតិសន្តិសុខសង្គម ដែលមានភារៈកិច្ចដឹកនាំ និងអនុវត្តរបបសន្តិសុខសង្គមក្នុងព្រះរាជាណាចក្រកម្ពុជា។ ប្រភពៈ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ (MoLVT)

១០. សៀវភៅណែនាំស្តីពីប្រាក់សោធន (NSSF Pension Guidebook). សៀវភៅនេះពន្យល់ពីលក្ខខណ្ឌ ទំហំនៃសោធន និងវិធីសាស្ត្រទាមទារ សម្រាប់សោធនជរាភាព ទុព្វលភាព ឧត្តរជីវី និងវិភាជន៍បូជាសព។ Retrieved from https://nssf.gov.kh/document

១១. ប.ស.ស. សេចក្តីណែនាំលេខ 012/20 សសស ចុះថ្ងៃទី១៥ ធ្នូ ២០២០ សេចក្តីណែនាំនេះស្តីពីការអនុវត្តន៍ផ្នែកប្រាក់សោធនសម្រាប់សមាជិក ប.ស.ស និងលក្ខខណ្ឌទាមទារសោធននានា. Retrieved from https://nssf.gov.kh

១២. ច្បាប់ស្តីពីរបបសន្តិសុខសង្គម ប្រលាសឱ្យប្រើនៅថ្ងៃទី១៨ ខែតុលា កថាភាគទី២ ផ្នែកប្រាក់សោធនតាមរបបភាគទានជាកាតព្វកិច្ចសម្រាប់បុគ្គលទាំងឡាយណាដែលស្ថិតក្រោមបទប្បញ្ញត្តិស្តីពីការងារ ដោយរួមបញ្ចូលទាំងបុគ្គលិកធ្វើការតាមផ្លូវអាកាសនិង នាវាសមុទ្រ ព្រមទាំងអ្នកបម្រើក្នុងផ្ទះ មាត្រា៣១ មាត្រា៣២ មាត្រា៣៣ មាត្រា៣៤

១៣. របាយការណ៍ប្រចាំឆ្នាំរបស់បេឡាជាតិសន្តិសុខសង្គមផ្តល់ព័ត៌មានស្ថិតិ និងលទ្ធផលអនុវត្តន៍ផ្នែកសន្តិសុខសង្គមនៅកម្ពុជា ដោយជាពិសេសផ្នែកប្រាក់សោធនប្រភព. Retrieved from https://nssf.gov.kh/report

១៤. បណ្ឌិត ហាប់ ផល្លី. (២០១៣). *សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច.*

១៥. បេឡាជាតិសន្តិសុខសង្គម. (មិនមានកំណត់ឆ្នាំ). ប្រព័ន្ធសន្តិសុខសង្គមនៅកម្ពុជា [Social Security System in Cambodia].ភ្នំពេញ. Retrieved from https://nssf.gov.kh/kh/social-security-system/
១៦. ILO (International Labour Organization). (2017). *World Social Protection Report 2017–19*. Universal social protection to achieve the Sustainable Development Goals. Geneva. Retrieved from https://www.ilo.org/global/publications/books/WCMS_604882/lang--en/index.htm
១៧. សហព័ន្ធសហជីពនិយោជិតកម្ពុជា (CAMFEBA). (2016). សេចក្តីណែនាំអំពីប្រព័ន្ធសន្តិសុខសង្គមនៅកម្ពុជា. ភ្នំពេញ
១៨. បេឡាជាតិរបបសន្តិសុខសង្គម (NSSF). (2020). *របាយការណ៍ស្តីពីការអភិវឌ្ឍន៍របបសន្តិសុខសង្គមកម្ពុជា* Retrieved from http://www.nssf.gov.kh
១៩. សម្ព័ន្ធសារព័ត៌មានកម្ពុជា. (2022). អត្ថបទស្តីពីប្រវត្តិសាស្ត្ររបបសន្តិសុខសង្គមនៅកម្ពុជា. សារព័ត៌មានសេដ្ឋកិច្ចជាតិ.
២០. គ.ស.ប. (Kingdom of Cambodia). (2002). ច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនដែលស្ថិតនៅក្រោមច្បាប់ការងារ។ រាជក្រឹត្យ និងច្បាប់ប្រកាសជាផ្លូវការ។
២១. United Nations. (1948). *Universal Declaration of Human Rights*. Article 22. Retrieved from https://www.un.org/en/about-us/universal-declaration-of-human-rights
២២. ILO (International Labour Organization) – Social Protection Floors Recommendation, 2012 (No. 202) Retrieved from https://www.ilo.org
២៣. United Nations. Universal Declaration of Human Rights (UDHR). Retrieved from https://www.un.org/en/about-us/universal-declaration-of-human-rights
២៤. បេឡាជាតិរបបសន្តិសុខសង្គម (NSSF). ផ្តល់*ព័ត៌មានលម្អិតអំពីប្រវត្តិរបស់បេឡា ប្រភេទសេវាកម្ម និងនីតិវិធីក្នុងការទទួលប្រាក់សោធន*. Retrieved from https://www.nssf.gov.kh
២៥. World Bank. *គោលនយោបាយ និងអភិវឌ្ឍការថែទាំសុខភាព និងសេវាសង្គមសម្រាប់ប្រទេសកំពុងអភិវឌ្ឍ*. Retrieved from https://www.worldbank.org
២៦. អង្គភាពអំណាចសន្តិសុខសង្គមជាតិ (NSSF). (មិនបានបញ្ជាក់ឆ្នាំ). ចក្ខុវិស័យ និងភារកិច្ច. Retrieved from https://www.nssf.gov.kh
២៧. អង្គភាពអំណាចសន្តិសុខសង្គមជាតិ (NSSF). (មិនបានបញ្ជាក់ឆ្នាំ). អំពីអង្គភាពអំណាចសន្តិសុខសង្គមជាតិ. Retrieved from https://www.nssf.gov.kh/default/about
២៨. ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ(២០២៣)។ របាយការណ៍ប្រចាំឆ្នាំស្តីពីការអនុវត្តន៍នៃប្រព័ន្ធសន្តិសុខសង្គម។ រាជធានីភ្នំពេញ៖ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។
២៩. រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។ (២០១៧)។ អនុក្រឹត្យលេខ ១៤០ ស្តីពី ការរៀបចំ និងអនុវត្តន៍រចនាសម្ព័ន្ធរបស់អង្គភាពអំណាចសន្តិសុខសង្គមជាតិ។
៣០. អង្គការជាតិការងារ (ILO)។ (២០២០). *ទិដ្ឋភាពទូទៅស្តីពីការការពារសង្គមនៅកម្ពុជា*. Retrieved from https://www.ilo.org
៣១. បេឡាជាតិសន្តិសុខសង្គម. (2023). របាយការណ៍ប្រចាំឆ្នាំ ២០២២. ភ្នំពេញ៖ បេឡាជាតិសន្តិសុខសង្គម។ Retrieved from https://www.nssf.gov.kh

៣២. ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ (2017)។ ប្រកាសលេខ ៤៤៨ ស្តីពីការអនុវត្តយុទ្ធនាការសន្តិសុខសង្គមផ្នែកប្រាក់សោធននិវត្តន៍។ ភ្នំពេញ៖ រដ្ឋាភិបាលកម្ពុជា។ ទាញយកពី https://www.mlvt.gov.kh

៣៣. អង្គការសង្គមការងារអន្តរជាតិ។ (2021)។ ការការពារសង្គមនៅកម្ពុជា៖ ការស្ថាបនាប្រព័ន្ធសុវត្ថិភាព និងបូកបញ្ចូលគ្នាដែលមានចីរភាព។ ក្រុមការងារផ្នែកអាស៊ីនៃ ILO។ ទាញយកពី https://www.ilo.org/asia/publications/WCMS_819194/lang--en/index.htm

៣៤. ធនាគារពិភពលោក។ (2019)។ឆ្ពោះទៅប្រព័ន្ធការពារសង្គមដែលគ្រប់គ្រាន់ មានប្រសិទ្ធភាព និងសមស្របនៅកម្ពុជា។ វ៉ាស៊ីនតោន, សហរដ្ឋអាមេរិក៖ ធនាគារពិភពលោក។ ទាញយកពី https://documents.worldbank.org

៣៥. រដ្ឋាភិបាលកម្ពុជា។ (2002)។ ច្បាប់ស្តីពីប្រព័ន្ធសន្តិសុខសង្គមសម្រាប់បុគ្គលដែលបានកំណត់ក្នុងច្បាប់ការងារ។ ភ្នំពេញ៖ រដ្ឋសភា។ ទាញយកពី https://www.nssf.gov.kh

# <u>ឧបសម្ព័ន្ធ</u>




សំណង់អគារ បេឡាជាតិសន្តិសុខសង្គម ខណ្ឌសែនសុខ



សកម្មភាពចុះបញ្ជីរបស់បេឡាជាតិសន្តិសុខសង្គម




ប័ណ្ណសមាជិកបេឡាជាតិសន្តិសុខសង្គម


ឯកសារសំខាន់ៗ
សម្រាប់ស្នើសុំ
ប្រាក់សោធន
ជរាភាព
រួមមាន៖
១ ប័ណ្ណសមាជិក ប.ស.ស.
២ អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ
ឬលិខិតឆ្លងដែន (ជនបរទេស)
៣ សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍
និងសេចក្តីចម្លងសំបុត្របញ្ជាក់កំណើតកូន (បើមានកូន)
៤ លេខគណនីធនាគារ អេស៊ីលីដា
ឬលេខគណនីធនាគារ កាណាឌីយ៉ា
មាន ប.ស.ស. មានការគាំពារគ្រប់ពេលវេលា!
សេវាផ្តល់ព័ត៌មាន
១២៩៧
១២៨៦
២៤ម៉ោង/៧ថ្ងៃ